# ចូលរួម ឬមិនចូលរួម ៖ ភាពស្ទាក់ស្ទើរក្នុងការចូលរួមជាមួយ តុលាការព្រហ្មទណ្ឌអន្តរជាតិនៅអាស៊ី

ម៉ាក ហ្វីនឡេយ៍ (Mark Findlay)[1]

អ្នកគាំទ្រតុលាការព្រហ្មទណ្ឌអន្តរជាតិបានអះអាងថា វាមានភាពចាំបាច់ត្រូវតែសម្រេចឲ្យបាននូវការផ្តល់សច្ចាប័នជាសកល ដើម្បីឲ្យមនុស្សភាគច្រើនលែងស្ថិតនៅក្រៅការការពារពីតុលាការព្រហ្មទណ្ឌអន្តរជាតិ ។ ការផ្តល់សច្ចាប័នរបស់ប្រជាជាតិនៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិកលើលក្ខិកៈទីក្រុងរ៉ូមនៅមានកម្រិតទាបនៅឡើយ ។ អត្ថបទនេះបានស្នើឲ្យមានការរៀបចំលំដាប់ថ្នាក់នៃការជំទាស់នឹងការផ្តល់សច្ចាប័ននៅក្នុងតំបន់នេះ ដោយទទួលស្គាល់ថា នៅក្នុងការស្ទាបស្ទង់មើលពីហេតុផលនៃការរឹងទទឹងមិនផ្តល់សច្ចាប័នលើយន្តការយុត្តិធម៌ព្រហ្មទណ្ឌអន្តជាតិ ចាប់ពីកម្រិតតំបន់ទៅដល់កម្រិតសកលនៅទូទាំងតំបន់អាស៊ី និងប៉ាស៊ីហ្វិក ដែលនៅមានភាពប្រថុយប្រថាន ទាំងការពិនិត្យមើលជ្រុលពេកលើភាពខុសគ្នានៃវប្បធម៌ និងនយោបាយ និងទាំងការស្វែងរកគោលគំនិតជាសកលដោយមិនគិតដល់លក្ខណៈពិសេសនៃយុត្តាធិការរបស់តុលាការប្រទេសនីមួយៗ ។ បន្ទាប់ពីរៀបចំលំដាប់ថ្នាក់នេះ អត្ថបទនេះរកឃើញដោយផ្អែកនូវរឿងប្លែកមួយដែលថា នៅតំបន់អាហ្វ្រិក និងអាមេរិកខាងត្បូង ដែលមានការជំទាស់នឹងការឲ្យសច្ចាប័ននេះ បែរជាដំណើរការនៃការផ្តល់សច្ចាប័នមានការរីករាលដាលខ្លាំងជាងទៅវិញ ។

**១. សេចក្តីផ្តើម**

**២. ទស្សនៈយល់ឃើញពីកម្រិតកំពូល - ហេតុអ្វីត្រូវចូលរួម?**

**៣. ការចាប់ផ្តើមការជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិ**

**៤. ការមិនផ្តល់សច្ចាប័ន ក្រៅពីអចិន្ត្រៃយ៍ និងអត្ថប្រយោជន៍?**

---

[1] សាស្ត្រាចារ្យផ្នែកច្បាប់នៅ Singapore Management University, សាស្ត្រាចារ្យផ្នែកយុត្តិធម៌ព្រហ្មទណ្ឌនៅ University of Sydney ។

**៥. ផលប្រយោជន៍ជាតិនិងផលប្រយោជន៍សកលៈដំណើររឿងនៃកាលានុវត្តន៍នយោបាយ**

**៦. មូលហេតុនៃការមិនផ្តល់សច្ចាប័ននៅក្នុងតំបន់ ៖ ភាពរសើបរបស់រដ្ឋ និងភាពស្មុគស្មើរនៅក្នុងតំបន់**

*៦.១. ភាពទាក់ទងគ្នា?*

*៦.២. ការឈានទៅដល់កម្រិតសកល*

*៦.៣. សំណល់ក្រោយអាណានិគម*

*៦.៤. អត្តសញ្ញាណវិធានបទដ្ឋាន*

*៦.៥. ធម្មនុញ្ញភាព*

*៦.៦. ឆន្ទានុសិទ្ធិប្រតិបត្តិ*

*៦.៧. សង្គមស៊ីវិល*

**៧. សេចក្តីបញ្ចប់**

## ១. សេចក្តីផ្តើម

តុលាការព្រហ្មទណ្ឌអន្តរជាតិអចិន្ត្រៃយ៍ត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៩៩៨[២] ប៉ុន្តែ ដើម្បីឲ្យតុលាការនេះក្លាយទៅជាស្ថាប័នយុត្តិធម៌សកលដែលអាចជឿជាក់បានក្នុងការអនុវត្តច្បាប់ព្រហ្មទណ្ឌអន្តរជាតិ និងបង្ហាញឲ្យឃើញជាក់ស្តែងនូវយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិសកល ការផ្តល់សច្ចាប័នលើលក្ខន្តិកៈទីក្រុងរ៉ូម គឺត្រូវសំដៅទៅរកការប្តេជ្ញាចិត្តចូលរួមជាលក្ខណៈអន្តរជាតិ ។ សេចក្តីប៉ងប្រាថ្នាចង់ឲ្យតុលាការដើរតួជាអ្នកទប់ស្កាត់ និងធានាឲ្យបាននូវការលុបបំបាត់និទ្ទណ្ឌភាព ពុំអាចយកធ្វើជាអំណះអំណាងបានទេ ប្រសិនបើការផ្តល់សច្ចាប័នដ៏ទូលំទូលាយ និងកិច្ចសហប្រតិបត្តិការយ៉ាងសកម្មសម្រេចមិនបាននោះ ។ ប្រសិនបើគ្មានមូលដ្ឋានទាំងអស់នេះ គោលបំណងជាផ្លូវការនឹងមិនមានសម្រាប់ធ្វើការវាយតម្លៃឲ្យផុតពីពាក្យចោទថា គឺជាការចាប់ផ្តើមដំណើរការដែលមានលក្ខណៈនយោបាយ និងកាត់ទោសដោយរើសមុខ ។[៣]

---

[២] លក្ខន្តិកៈទីក្រុងរ៉ូមនៃតុលាការព្រហ្មទណ្ឌអន្តរជាតិរបស់អង្គការសហប្រជាជាតិ Doc. A/CONF.183/9 (១៧ កក្កដា ១៩៩៨) [លក្ខន្តិកៈទីក្រុងរ៉ូម] ។

[៣] សម្រាប់ការពិភាក្សាចំពោះបញ្ហាទាំងពីរ សូមមើល MARK FINDLAY, INTERNATIONAL AND COMPARATIVE CRIMINAL JUSTICE: A CRITICAL INTRODUCTION, ជំពូកទី៣ (Routledge ២០១៣) ។

អត្ថបទនេះសំដៅពិនិត្យមើលលើមូលហេតុនៃការស្ទាក់ស្ទើរ ក្នុងការផ្តល់សច្ចាប័នលើលក្ខន្តិកៈទីក្រុងរ៉ូមក្នុងបរិបទនៃវប្បធម៌-នយោបាយដ៏ជាក់លាក់មួយ ។ ការពិភាក្សាចាប់ផ្តើមពីក្នុងកម្រិតជាទូទៅ ដោយពិនិត្យមើលលើបញ្ហាដែលកំណត់ពីចំណុចផ្តួចផ្តើមនៃនីតិវិធីរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ : ការចាប់ផ្តើមការស៊ើបអង្កេត និងបន្ទាប់មក គឺការចោទប្រកាន់នៅកម្រិតតុលាការព្រហ្មទណ្ឌអន្តរជាតិ និងសារជាតិនយោបាយ ដោយសារតែឥទ្ធិពលនៃការប្រកាន់បក្សពួករបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ។ បន្ទាប់មក អត្ថបទនេះនិយាយពីរបៀបដែលអង្គការសហប្រជាជាតិ និងរដ្ឋជាសមាជិក ដាក់(ខ) លើកលែងចំពោះអ្នកដែលចូលរួមក្នុងប្រតិបត្តិការរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ ឬផ្សេងពីនេះ ពីការទទួលខុសត្រូវមានប្រសិទ្ធិភាពនៅចំពោះមុខតុលាការព្រហ្មទណ្ឌអន្តរជាតិ ។ បន្ទាប់មក អត្ថបទនេះបានផ្តោតលើទីតាំងជាលក្ខណៈតំបន់/វប្បធម៌ (ជាជាងទៅលើឥទ្ធិពល/នយោបាយ) នៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក ដែលមានការរឹងទទឹងគួរឲ្យកត់សម្គាល់នឹងការផ្តល់សច្ចាប័ន ។ ការធ្វើរបៀបនេះ នឹងអនុញ្ញាតឲ្យមានការរៀបចំចំណាត់ថ្នាក់ជាទូទៅមួយអំពីភាពខុសប្លែកគ្នានៃហេតុផលរឹងទទឹងនៅក្នុងលក្ខខណ្ឌបរិបទជាក់លាក់ ដែលជួយនឹងអ្នកដែលព្យាយាមភ្ជាប់ទំនាក់ទំនងពិសេសរវាងការផ្តល់សច្ចាប័នជាសកល និងការសម្រេចឲ្យបាននូវគោលបំណងការពារកុំឲ្យមានឧក្រិដ្ឋកម្មទ្រង់ទ្រាយធំរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ។

ក្នុង«ការដកហត្ថលេខា»[៤] ចេញពីលក្ខន្តិកៈទីក្រុងរ៉ូមដោយសហរដ្ឋអាមេរិក អតីតប្រធានាធិបតី George W. Bush បាននិយាយសំដៅទៅ«មនុស្សមួយក្រុមដែលចង់កាត់ទោសទាហានរបស់យើង» ។[៥] ដើម្បីទប់ទល់នឹងភាពវើរវាយដែលចង់នាំកងទ័ពសហរដ្ឋអាមេរិក ទៅកាត់ទោសនៅចំពោះមុខតុលាការព្រហ្មទណ្ឌអន្តរជាតិ ព្រឹទ្ធសភាសហរដ្ឋអាមេរិកបានអនុម័តច្បាប់ការពារសមាជិកបម្រើការអាមេរិកាំង

---

[៤] នៅក្នុងឆ្នាំ២០០០ អតីតប្រធានាធិបតីសហរដ្ឋអាមេរិក ចុះហត្ថលេខាលើសន្ធិសញ្ញាដែលសហរដ្ឋអាមេរិកគួរតែមានឱកាសក្នុងការត្រួតពិនិត្យ និងវាយតម្លៃមុខងាររបស់តុលាការមុននឹងចង់ស្ថិតនៅក្រោមយុត្តាធិការរបស់តុលាការ ។ ទោះបីជាយ៉ាងណាក៏ដោយ លោកបានចង្អុលបង្ហាញថា លោកនឹងមិនផ្ញើសន្ធិសញ្ញានោះជូនព្រឹទ្ធសភាសម្រាប់ការផ្តល់សច្ចាប័ន ។ អ្នកបន្តតំណែងរបស់ លោក គឺ ចច ដាប់បែលយូ ប៊ូស មិនចុះហត្ថលេខាលើសន្ធិសញ្ញានៅឆ្នាំ ២០០២ដោយផ្តល់ដំណឹងជូនអង្គការសហប្រជាជាតិថា សហរដ្ឋអាមេរិកមិនមានបំណងធ្វើជាសមាជិកទេ ហើយមិនទទួលស្គាល់កាតព្វកិច្ចច្បាប់ណាមួយដែលកើតចេញពីការចុះហត្ថលេខាពីមុនឡើយ ។

[5] យោងតាម James Carroll, Op Ed: *Much to Gain for US in World Court*, BOSTON GLOBE ( ២៦ មីនា, ២០១២), អាចរកបាននៅគេហទំព័រ http://www.bostonglobe.com/opinion/2012/03/25/much-gain-for-world-court/o5RSzho03iGpSfnC8tNYUI/story.html.

American Service-Members Protection Act[6] ដោយផ្នែក ជាការអះអាងអំពីស្វ័យភាព និង អធិបតេយ្យភាព នៅចំពោះយុត្តាធិការរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ។ តាំងតែពីពេលនោះមក ជំហររបស់សហរដ្ឋអាមេរិកបានផ្លាស់ប្តូរពីភាពពុំយល់ស្របទៅជាកិច្ចសហប្រតិបត្តិការដែលមានលក្ខណៈ ដោយផ្នែក ។

មានការលើកអំណះអំណាងដែលគួរឲ្យជឿជាក់បានថា មហាអំណាចពិភពលោកដែលមានទំនាក់ទំនងអន្តរជាតិទូលំទូលាយ ដែលជំពាក់ជាក់រិន និងមានវត្តមានជាច្រើនកន្លែង ដែលអាចជាប់ពាក់ព័ន្ធនឹងយុត្តាធិការរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ គឺប្រយ័ត្នប្រយែងចំពោះតុលាការអន្តរជាតិ ដែលមានលក្ខណៈនយោបាយនេះ ។[៧] ភាពមន្ទិលសង្ស័យមួយចំនួនអាចកើតមានចំពោះការដែលថា ការបដិសេធរបស់សហរដ្ឋអាមេរិក ចិន ឥណ្ឌា និងរុស្ស៊ី មិនទទួលយកយុត្តាធិការរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ បានជះឥទ្ធិពលអវិជ្ជមានយ៉ាងធ្ងន់ធ្ងរទៅលើរដ្ឋតូចតាចដែលមានភាពមិនច្បាស់លាស់អំពីអត្ថប្រយោជន៍នៃច្បាប់អន្តរជាតិ និងស្ថាប័នបែបនេះ ។

សូម្បីតែដោយអ្នករិះគន់តុលាការនេះ ក៏មានការទទួលស្គាល់ថា តុលាការព្រហ្មទណ្ឌអន្តរជាតិមានតួនាទីបន្ទាន់ក្នុងការសង្គ្រោះប្រជាពលរដ្ឋ ដែលកំពុងទទួលរងការរំលោភបំពានយ៉ាងឃោរឃៅពីសំណាក់រដ្ឋាភិបាលរបស់ខ្លួន ។[៨] លើសពីនេះទៀត សាសនា និងវប្បធម៌ប្លែកៗតាមតំបន់ ដូចជានៅអាស៊ី ជួបប្រទះហានិភ័យ ដោយហេតុថា សារសំខាន់នៃវប្បធម៌ដ៏សំខាន់ និងប្រពៃណីច្បាប់ អាចនឹងត្រូវធ្វើឲ្យប៉ះពាល់ដោយតុលាការអន្តរជាតិ និងដំណើរការធ្វើច្បាប់របស់តុលាការនេះ ដែលត្រូវបានបង្កើតឡើងដោយគ្មានឥទ្ធិពលពីប្រទេសទាំងនេះឡើយ ។

ខ្ញុំបានលើកអំណះអំណាងថា វាមានសារសំខាន់ណាស់សម្រាប់ផ្នែកយុត្តិធម៌ព្រហ្មទណ្ឌ ក្រៅពីប្រទេសប្រើប្រព័ន្ធច្បាប់ស៊ីវិល និងច្បាប់ខមមិនឡ ជាពិសេសប្រទេសដែលមានប្រពៃណីប្រព័ន្ធច្បាប់ចម្រុះនៅទូទាំងអាស៊ី និងប៉ាស៊ីហ្វិក ក្នុងការចូលរួមជាមួយតុលាការព្រហ្មទណ្ឌអន្តរជាតិ ដើម្បីឲ្យឥទ្ធិពលនីតិវិធី ដែលអវត្តមានកាលពីមុនទៅលើការអភិវឌ្ឍច្បាប់ព្រហ្មទណ្ឌអន្តរជាតិ និងដំណើរការទាំងនេះ

---

៦ American Service-Members' Protection Act of ២០០២ (H.R. ៤៧៧៥), ច្បាប់សាធារណៈលេខ. ១០៧-២០៦ ។

៧ សូមមើល *generally* FINDLAY, កំណត់ចំណាំ ៣, ជំពូក៣ ។

៨ Carroll, កំណត់ចំណាំ៥ ។

អាចបញ្ជាក់ថាត្រឹមត្រូវតាមផ្លូវច្បាប់នូវគោលបំណងរបស់ច្បាប់ព្រហ្មទណ្ឌជាសកល ។[៩] តាមរយៈការកើនឡើងកាន់តែច្រើន នូវការចូលរួមផ្នែកនីតិវិធីពីប្រទេសផ្សេងៗច្រើនជាងមុននោះ ភាពស្របច្បាប់របស់តុលាការព្រហ្មទណ្ឌអន្តរជាតិក៏នឹងកើនឡើង និងកាត់បន្ថយនូវឥទ្ធិពលលើសលុបរបស់ប្រទេសធំៗ ។ អង្គការសម្ព័ន្ធមិត្តសម្រាប់តុលាការព្រហ្មទណ្ឌអន្តរជាតិ (Coalition for the ICC)[១០] និងសាខារបស់អង្គការនេះនៅអាស៊ី[១១] ប្រកាសថា មានតែតាមរយៈការផ្តល់សច្ចាប័នដ៏ទូលំទូលាយ[១២] លើលក្ខន្តិកៈទីក្រុងរ៉ូមប៉ុណ្ណោះ ទើបអាចធានាបាននូវឯករាជភាពរបស់តុលាការ និងការលុបបំបាត់នូវនិទ្ទណ្ឌភាព ។[១៣]

ការវិភាគបន្តទៀតនេះ មិនបានស្នើឡើងថា ឥទ្ធិពលអវិជ្ជមាននៃភាពស្ទាក់ស្ទើរនិងផលប្រយោជន៍ផ្ទាល់ខ្លួនរបស់មហាអំណាចពិភពលោក ឬ ភាពខ្វែងគំនិតគ្នាថ្នាក់តំបន់ និងថ្នាក់ជាតិ ជាមូលហេតុនាំឲ្យអាស៊ី និងប៉ាស៊ីហ្វិក មិនមានតំណាងច្រើនក្នុងចំណោមរដ្ឋសមាជិករបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ

---

[៩] សូមមើល *generally* Mark Findlay, *The Challenges for Asian Jurisdictions in the Development of International Criminal Justice*, ៣២ SYDNEY L. REV. ២០៥, ២១៥-២៣៦ (២០១០) ។

[១០] គេហទំព័រ Coalition for the International Criminal Court, http://www.iccnow.org/.

[១១] គេហទំព័រ Coalition for the International Criminal Court, Asia and the Pacific region, គេហទំព័រ http://coalitionfortheicc.org/?mod=region&idureg=7.

[១២] ក្នុងចំណោមរដ្ឋជាសមាជិកចំនួន ២៤នៃតុលាការព្រហ្មទណ្ឌអន្តរជាតិ នៅអាស៊ី មានតែ៩ប្រទេស (អាហ្វហ្កានីស្ថាន, បង់ក្លាដែស, កម្ពុជា, ម៉ាឌីវ, ម៉ុងហ្គោលី, ហ្វីលីពីន, សាធារណរដ្ឋកូរ៉េ, សាធារណរដ្ឋទីម័រឡេស្ត និងជប៉ុន) ដែលបានផ្តល់សច្ចាប័នលើលក្ខន្តិកៈទីក្រុងរ៉ូម ។ តំបន់អាស៊ីនៅតែមិនតំណាងបាននៅតុលាការ បើទោះបីជាសង្គមស៊ីវិលកំពុងធ្វើការយ៉ាងសកម្មលើយុត្តិធម៌អន្តរជាតិ និងនីតិរដ្ឋនៅទូទាំងឧបទ្វីបនេះក៏ដោយ ។ ក្នុងចំណោះរដ្ឋជាសមាជិករបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ មានតែសាធារណរដ្ឋកូរ៉េមួយគត់ បានអនុម័តច្បាប់សម្រាប់អនុវត្ត ។ ប្រទេសអាហ្វហ្កានីស្ថានកំពុងចាត់វិធានការសមរម្យ នៅក្នុងការសម្របសម្រួលជាមួយក្រុមសង្គមស៊ីវិលដើម្បីផ្តួចផ្តើមដំណើរការធ្វើច្បាប់សម្រាប់អនុវត្ត ហើយម៉ុងហ្គោលីបានបង្កើតក្រុមការងារតុលាការព្រហ្មទណ្ឌអន្តរជាតិ ដើម្បីពិភាក្សា និងតាមដានការប្រតិបត្តិរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិកាលពីប៉ុន្មានឆ្នាំកន្លងមក ប៉ុន្តែដំណើរការនេះបានជាប់គាំងមួយរយៈនេះ ។ ប្រទេសកម្ពុជានិងទីម័រខាងកើត បានចាត់ការសន្សឹមៗដូចគ្នា នៅក្នុងការអនុវត្តកាតព្វកិច្ចជាបន្ទាន់ដោយប្រសិទ្ធភាព តាមលក្ខន្តិកៈទីក្រុងរ៉ូម ។ នៅក្នុងតំបន់មានតែសាធារណរដ្ឋកូរ៉េបានផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀងស្តីពីបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិរបស់តុលាការ(APIC) ។ ទោះបីជាម៉ុងហ្គោលីជាប្រទេសហត្ថលេខីក៏ដោយ គឺចាំបាច់ត្រូវចាត់ការបន្តទៀត ហើយផ្តល់សច្ចាប័នលើលិខិតូបករណ៍សំខាន់នេះ ។

[13] Coalition for the International Criminal Court Asia Pacific Regional Strategy Meeting, Quezon City, The Philippines (Apr. 11-12, 2011), នៅគេហទំព័រ http://www.iccnow.org/documents/CICC_Asia_RSM_April_2011_Final_Recommendations.pdf.

នោះទេ ។ ការពន្យល់គឺ អាស្រ័យទៅតាមទីកន្លែង និងភាពជាក់ស្ដែង ដោយរាប់តាំងពីអសមត្ថភាពក្នុងការអនុម័តឲ្យទៅជាច្បាប់ រហូតដល់ភាពមន្ទិលសង្ស័យខាងនយោបាយយ៉ាងធ្ងន់ធ្ងរ ដែលត្រលប់ទៅតាំងពីមុនពេលទទួលបានឯករាជ្យ និងតាមរយៈការកសំណល់អាណានិគម ។ អត្ថបទនេះផ្ដល់ជាគំនិតថា ដើម្បីធានាឲ្យបាននូវគោលនយោបាយជោគជ័យ ដែលនាំឲ្យមានការចូលរួមពីថ្នាក់តំបន់ផ្សេងៗដ៏ទូលំទូលាយទៅក្នុងបេសកកម្មរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ជាដំបូង ត្រូវតែប្រឈមមុខ និងដោះស្រាយនូវមូលហេតុពិសេសដែលនាំឲ្យប្រទេសនីមួយៗមិនចូលរួមតុលាការព្រហ្មទណ្ឌអន្តរជាតិ ហើយបន្ទាប់មកតាមរយៈការរកឃើញនូវមូលហេតុជំទាស់នឹងតុលាការនៅក្នុងតំបន់ទាំងមូល ព្យាយាមឆ្លើយតបនឹងមូលហេតុទាំងនេះឲ្យបានត្រឹមត្រូវតាមច្បាប់ ជាជាងត្រឹមការសន្យាចោល ។[១៤] បន្ទាប់ពីយល់ដឹងពីបញ្ហាទាំងអស់នេះ យើងនឹងអាចរៀបចំអំណះអំណាងដើម្បីគាំទ្រឲ្យមានការផ្ដល់សច្ចាប័ន លើការចូលរួមនៅក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិកាន់តែខ្លាំងឡើងនៅក្នុងតំបន់ និងកាន់តែមានប្រយោជន៍ដល់ការអភិវឌ្ឍតុលាការយុត្តិធម៌អន្តរជាតិ និងយុត្តិសាស្ត្រទាំងមូលសម្រាប់ប្រជាជនទាំងអស់គ្នា ។ ការជំរុញឲ្យផ្ដល់សច្ចាប័នពីតុលាការព្រហ្មទណ្ឌអន្តរជាតិ និងអង្គការសម្ព័ន្ធមិត្តសម្រាប់តុលាការព្រហ្មទណ្ឌអន្តរជាតិ មិនមែនកើតឡើងក្នុងលក្ខណៈជាការដាក់អាណានិគមរបស់លោកខាងលិចនោះទេ ប៉ុន្តែជាឱកាសជំរុញឲ្យទំនៀមទម្លាប់អនុវត្តរបស់តំបន់អាស៊ី និងប៉ាស៊ីហ្វិក ឲ្យឈានដល់កម្រិតសមរម្យមួយដែលមានការទទួលស្គាល់នៅក្នុងសណ្ដាប់ធ្នាប់យុត្តិធម៌សកលថ្មីមួយ ។

## ២. ទស្សនៈយល់ឃើញពីកម្រិតកំពូល-ហេតុអ្វីត្រូវចូលរួម?

ក្នុងបទបង្ហាញនៅ Wallace Wurth Memorial[១៥] នាពេលថ្មីៗនេះ ប្រធានតុលាការព្រហ្មទណ្ឌអន្តរជាតិ ចៅក្រម សាងយុន សុង (Sang-Hyun Song) បានបង្ហាញពីចំណាប់អារម្មណ៍ពាក់ព័ន្ធនឹងការចូលរួមជារដ្ឋសមាជិក ។ អ្នកចូលរួមនៅទីនោះរួមមានតំណាងរាជរដ្ឋាភិបាលនៃប្រទេសនៅតំបន់អាស៊ី

---

១៤ MARK FINDLAY & RALPH HENHAM, BEYOND PUNISHMENT: ACHIEVING INTERNATIONAL CRIMINAL JUSTICE, ជំពូក ៨ (Palgrave Macmillan ២០០៩).

១៥ ចៅក្រម Sang-Hyun Song, *From Punishment to Prevention: Reflections on the Future of International Criminal Justice*, Wallace Wurth Memorial Lecture, Univ. of New South Wales, Sydney (១៤ កុម្ភៈ ២០១២), អាចរកបាននៅគេហទំព័រ http://www.icc-cpi.int/NR/rdonlyres/29D0B2A7-71D4-457A-B9A3-9AC4E78DD968/284266/120214ICCPresidentUNSWWallaceWurthmemoriallecture.pdf

និងប៉ាស៊ីហ្វិកដែលមិនទាន់ផ្តល់សច្ចាប័នលើលក្ខន្តិកៈទីក្រុងរ៉ូម ហើយអំណះអំណាងជាច្រើនត្រូវបានលើកឡើងនៅក្នុងអំឡុងពេលនៃបទបង្ហាញនោះ ។

ការលើកឡើងរបស់លោកប្រធានតុលាការព្រហ្មទណ្ឌអន្តរជាតិមានដូចតទៅៈ

- ឥទ្ធិពលអំពីការការពារកុំឲ្យមានឧក្រិដ្ឋកម្មអន្តរជាតិទ្រង់ទ្រាយធំ របស់តុលាការព្រហ្មទណ្ឌអន្តរជាតិ គឺជាសមត្ថភាពដែលគួរឲ្យទាក់ទាញ សម្រាប់យុត្តិធម៌ និងការកសាងសន្តិភាព ។
- ជាពិសេស ការរារាំងកុំឲ្យកើតឡើងនៅពេលអនាគត, អន្តរាគមន៍ទាន់ពេលវេលា, ឯករាជភាពនៃការស៊ើបអង្កេតបឋម, រួមចំណែកដល់ស្ថេរភាពសម្រាប់រយៈពេលខ្លីខាងមុខ និងសមភាពយូរអង្វែង[១៦] ការផ្តល់អំណាចដល់ជនរងគ្រោះតាមរយៈការចូលរួមស្វែងរកយុត្តិធម៌ដោយអនុលោមតាមសិទ្ធិរបស់ខ្លួន ព្រមទាំងការជួយជ្រោមជ្រែងជនរងគ្រោះ ដើម្បីទទួលបានការទទួលស្គាល់អំពីតម្រូវការក្រៅផ្លូវតុលាការ[១៧] ដែលទាំងអស់នេះ នឹងជួយបង្កើនសមត្ថភាពរបស់តុលាការក្នុងការរារាំងកុំឲ្យកើតឡើងឧក្រិដ្ឋកម្មបែបនោះនៅពេលអនាគត ។
- តួនាទីរបស់តុលាការនៅក្នុងការបង្កើតបទដ្ឋាន បានរួមបញ្ចូលនូវឥទ្ធិពលដែលមានសក្តានុពលបំផុតសម្រាប់ការកសាងសន្តិភាព ។ ក្នុងតួនាទីនេះ តុលាការទទួលស្គាល់នូវគម្លាតរវាងសន្និសញ្ញាអន្តរជាតិ និងបទដ្ឋានអនុវត្តក្នុងស្រុក ដែលត្រូវតែបង្រួមគ្នាមកវិញ ។
- តួនាទីបំពេញបន្ថែម (complementarity)[១៨] ជួយគាំទ្រកិច្ចខិតខំប្រឹងប្រែងរបស់សង្គមស៊ីវិលដើម្បីសន្តិភាព និងយុត្តិធម៌នៅក្នុងប្រទេសដែលទើបនឹងងើបចេញពីការតស៊ូក្រោយជម្លោះ ដោយផ្តល់សិទ្ធិ និងករណីកិច្ចចាំបាច់ឲ្យប្រទេសនីមួយៗស៊ើបអង្កេត និងកាត់ទោសឧក្រិដ្ឋកម្មដែលស្ថិតនៅក្រោមយុត្តាធិការរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ។ តួនាទីបំពេញបន្ថែម

---

[១៦] សូមមើលរបាយការណ៍អភិវឌ្ឍន៍នៃធនាគារពិភពលោក: *Conflict*, *Security and Development*, The International Bank for Reconstruction and Development / The World Bank (2011) (identifying transitional justice as forestalling cycles of violence in post conflict contexts), អាចរកបានតាមគេហទំព័រ http://siteresources.worldbank.org/INTWDRS/Resources/WDR2011_Full_Text.pdf ។

[១៧] ចៅក្រមបាននិយាយសំដៅដល់អ្នកទទួលផលផ្ទាល់ចំនួន ៤ម៉ឺននាក់ ពីដំណើរការនៃសំណងខូចខាតរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិដែលទាក់ទងនឹងការផ្តួចផ្តើមរបស់រដ្ឋាភិបាលជាច្រើន ដូចជាសហរដ្ឋអាមេរិក ដែលផ្តោតលើជនរងគ្រោះនៃអំពើហិង្សាផ្លូវភេទនៅសាធារណរដ្ឋអាហ្វ្រិកកណ្តាល ។

[១៨] សម្រាប់ការពិភាក្សាលម្អិតនៃគំនិតនេះ មើល FINDLAY, កំណត់ចំណាំពខាងដើម ជំពូក៣ ។

បានផ្សារភ្ជាប់មុខងារធ្វើឲ្យរាងចាល តាមរយៈការជួយសម្របសម្រួលកាត់ទោសឧក្រិដ្ឋកម្មប្រភេទនេះ តាមប្រទេសនីមួយៗ ដែលការធ្វើបែបនេះបានជួយពង្រឹងសមត្ថភាពរបស់ប្រទេសទាំងនោះផង ហើយតាមរយៈនេះ ក៏បានអនុវត្តនូវតួនាទីរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិនៅពេលដែលបទដ្ឋានច្បាប់អន្តរជាតិនៃលក្ខន្តិកៈទីក្រុងរ៉ូម ត្រូវបានបញ្ចូលទៅជាបទដ្ឋានក្នុងស្រុករបស់រដ្ឋនោះ ។

- ទោះបីជាប្រព័ន្ធយុត្តិធម៌ក្នុងស្រុកនៃរដ្ឋដែលបានបើកការស៊ើបអង្កេត និងកាត់ទោសឧក្រិដ្ឋកម្មដែលស្ថិតនៅក្នុងយុត្តាធិការរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិក៏ដោយ ក៏តុលាការនេះផ្តល់សំណាញ់សុវត្ថិភាពជូន ដើម្បីធានាឲ្យមានការទទួលខុសត្រូវរបស់រដ្ឋលើសមត្ថភាពនៃការស្វែងរកយុត្តិធម៌ផ្នែកព្រហ្មទណ្ឌ និងការផ្តល់សេវាពាក់ព័ន្ធ ។
- តុលាការព្រហ្មទណ្ឌអន្តរជាតិទទួលស្គាល់ភាពចំបាច់នៃកិច្ចសហប្រតិបត្តិការពីរដ្ឋ ដើម្បីផ្តល់អំណាចជូនតុលាការព្រហ្មទណ្ឌអន្តរជាតិក្នុងការចាប់ខ្លួន និងលទ្ធភាពប្រមូលភស្តុតាង និងលើកទឹកចិត្តសាក្សីឲ្យមកផ្តល់សក្ខីកម្ម ។
- លើសពីនេះទៀត មានតម្រូវការដើម្បីសម្រេចឲ្យបានភាពជាសកល ដើម្បីឲ្យមនុស្សជាតិភាគច្រើនដែលស្ថិតនៅក្រៅវង្វង់នៃការការពាររបស់លក្ខន្តិកៈទីក្រុងរ៉ូម អាចស្ថិតនៅក្នុងវង្វង់នៃការពាររបស់តុលាការព្រហ្មទណ្ឌអន្តរជាតិបាន ។

នៅក្នុងសេចក្តីថ្លែងបញ្ចប់ លោកប្រធានតុលាការព្រហ្មទណ្ឌអន្តរជាតិបានលើកឡើងម្តងទៀតនូវការយល់ដឹងពិតប្រាកដដែលថា សក្តានុពលនៅហ្នឹងកន្លែង និងភាពសមស្របតាមផ្លូវច្បាប់របស់អ្នកពាក់ព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិ មានសារសំខាន់ខ្លាំងណាស់សម្រាប់ការទទួលបានជោគជ័យរបស់តុលាការនេះ ។ ដោយហេតុនេះហើយ របៀបដែលសក្តានុពល និងភាពសមស្របតាមផ្លូវច្បាប់នៃស្ថាប័ន និងដំណើរការយុត្តិធម៌សកលលោក ត្រូវបានមើលឃើញ គឺខុសប្លែកគ្នាតាមវប្បធម៌ និងនយោបាយ និងប្រវត្តិសាស្រ្ត អាចពន្យល់ពីភាពមិនប្រក្រតីនៃសមាជិកភាពរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ។ ដូច្នេះ វាចាំបាច់ត្រូវតែធ្វើការវិភាគពីមូលដ្ឋានក្រោម-ឡើងលើអំពីភាពរឹងទទឹងចំពោះការផ្តល់សច្ចាប័ន ប្រសិនបើចង់ឲ្យតុលាការព្រហ្មទណ្ឌអន្តរជាតិជំរុញឲ្យមានការផ្តល់សច្ចាប័នជាលក្ខណៈសកលប្រកបដោយប្រសិទ្ធភាព និងភាពជឿជាក់បាន ។

ទោះបីជាយ៉ាងណាក៏ដោយ កម្លាំងជំទាស់នឹងសារជាតិ និងយុត្តាធិការតុលាការព្រហ្មទណ្ឌអន្តរជាតិ មិនអាចសន្មតថា ជាការជំទាស់ស្មើគ្នា ស៊ីសង្វាក់គ្នា ឬជាសកល ចំពោះការធ្វើអន្តរាគមន៍របស់ស្ថាប័នយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិសម្រាប់ការរក្សាសណ្តាប់ធ្នាប់សកលនោះទេ ។ ការពិចារណាជាសង្ខេបពីអំណាចរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ទាក់ទងនឹងស្ថាប័នយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិ (បញ្ជូនរឿងទៅតុលាការព្រហ្មទណ្ឌអន្តរជាតិ សម្រេចពីបេសកកម្មថែរក្សាសន្តិភាព និងគ្រប់គ្រងតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសអតីតយូហ្គោស្លាវី (ICTY) និងរ៉ូវ៉ាន់ដា) រួមផ្សំជាមួយនឹងសំណុំរឿងដែលកំពុងដំណើរការទាក់ទងនឹងដាហ្វ័រ នៅប្រទេសស៊ូដង់ផងនោះ គឺលាតត្រដាងឲ្យឃើញពីភាពសាំញ៉ាំនៃភាពតានតឹងរវាងអការៈមិនចូលរួមដែលស្តែងចេញតាមរយៈការមិនផ្តល់សច្ចាប័ន និងផលប្រយោជន៍ជាតិផ្ទាល់ខ្លួន នៅពីក្រោយការទប់ស្កាត់ឧក្រិដ្ឋកម្មអន្តរជាតិទៅតាមសំណុំរឿងនីមួយៗ សម្រាប់ការប្រើប្រាស់ដំណើរការរបស់តុលាការនេះ ។ ក្នុងការបង្ហាញពីគំនិតទាំងនេះ វាចាំបាច់ណាស់ដើម្បីយល់ដឹងពីអ្វីដែលជម្រុញឲ្យមានការជំនុំជម្រះឧក្រិដ្ឋកម្មអន្តរជាតិ និងដើម្បីយល់ពីភាពមន្ទិលសង្ស័យលើស្ថាប័នទាំងនោះ ព្រមទាំងពីដំណើរការយុត្តិធម៌ដែលមានលក្ខណៈនយោបាយ និងមានភាពលម្អៀង ។

## ៣. ការចាប់ផ្តើមការជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិ

ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ប្រតិបត្តិការនៅក្នុងភាពពិតសាំញ៉ាំនៃទំនាក់ទំនងអន្តរជាតិ ។ សេចក្តីសម្រេចក្នុងការចោទប្រកាន់ បានផ្តល់ជាឧទាហរណ៍ពីរបៀបដែលច្បាប់ព្រហ្មទណ្ឌអន្តរជាតិ (វិធាន និងនីតិវិធីច្បាប់) ដើរតួនាទីជាផ្នែកមួយនៃការធ្វើឲ្យមានតុល្យភាពអំណាចនៅក្នុងទំនាក់ទំនងអន្តរជាតិ ។[១៩] ឧទាហរណ៍ ការចោទប្រកាន់នៅតុលាការព្រហ្មទណ្ឌអន្តរជាតិ អាចផ្តួចផ្តើមឡើងតាមរយៈក្រុមប្រឹក្សាសន្តិសុខនៃអង្គការសហប្រជាជាតិ ឬពីរដ្ឋសមាជិកមួយ ដូចដែលមានចែង នៅក្នុងលក្ខន្តិកៈទីក្រុងរ៉ូម ឬបើពុំដូច្នេះទេ ព្រះរាជអាជ្ញានឹងប្រើប្រាស់ឆន្ទានុសិទ្ធិរបស់ខ្លួនដើម្បីធ្វើការចោទប្រកាន់ ។[២០] ម្យ៉ាងទៀត ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ អាចស្នើសុំព្រះរាជអាជ្ញាមិនឲ្យចាប់ផ្តើមស៊ើបអង្កេត ឬចោទប្រកាន់ក្នុងរយៈពេល១២ខែ (ជាយុទ្ធសាស្ត្រពន្យារពេល ឬហាមឃាត់ ដែលអាចស្នើសុំសាជាថ្មីបាន) ។[២១]

---

[១៩] សូមមើលជាទូទៅ Mark Findlay & Clare McLean, *Emerging International Criminal Justice*, ១៨:៣ CURRENT ISSUES IN CRIM. J. ៤៥៧ (២០០៧) ។

[២០] លក្ខន្តិកៈទីក្រុងរ៉ូម, កំណត់ចំណាំខាងដើម ២ មាត្រា ១៣(ខ) ។

[២១] ស្អួន កំណត់ចំណាំ មាត្រា ១៦ ។

ដូច្នេះ ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ មានទំនាក់ទំនងនយោបាយជាមួយតុលាការព្រហ្មទណ្ឌអន្តរជាតិតាមរយៈអំណាចផ្តួចផ្តើម និងគាំទ្រ ដោយការបញ្ជូនរឿងក្តីឲ្យស៊ើបអង្កេត និងចោទប្រកាន់[២២] និងដោយពន្យារពេលស៊ើបអង្កេត ឬចោទប្រកាន់រឿងក្តីមួយ សម្រាប់រយៈពេលកំណត់មួយ ឬរយៈពេលបន្តមួយ ។[២៣] ការគ្រប់គ្រងដ៏មានឥទ្ធិពល ដែលអនុវត្តដោយសមាជិកក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ និងដែលជំរុញដោយផលប្រយោជន៍ផ្ទាល់ខ្លួននៅក្រោយសិទ្ធិជំទាស់ (សិទ្ធិវេតូ) ទំនងជាមានផលនៅក្នុងការវិនិយោគនៅក្នុងសមាជិកអចិន្ត្រៃយ៍របស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ជាពិសេស សហរដ្ឋអាមេរិក និងចិន ដែលមានអំណាចក្នុងការស្នើបញ្ជូនសំណុំរឿងឲ្យស៊ើបអង្កេត (តាមរយៈសេចក្តីសម្រេចក្នុងការបញ្ជូនសំណុំរឿងទៅតុលាការព្រហ្មទណ្ឌអន្តរជាតិ, ការបោះឆ្នោតវេតូប្រឆាំងនឹងសេចក្តីសម្រេចណាដែលជុយនឹងផលប្រយោជន៍របស់ខ្លួន, ឬការផ្តួចផ្តើមស៊ើបអង្កេត ឬជំនុំជម្រះតាមវិធីណាក៏ដោយ, ការពន្យារពេលការចាប់ផ្តើម ឬដំណើរការតាមតែអំពើចិត្តរបស់ខ្លួន) ។[២៤]

ភាពជាប់ពាក់ព័ន្ធដ៏ស្មុគស្មាញរវាងតុលាការព្រហ្មទណ្ឌអន្តរជាតិ និងក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ឆ្លុះបញ្ចាំងឲ្យឃើញពីទំនាក់ទំនងដែលមិនអាចជៀសរួចរវាងប្រតិបត្តិការផ្លូវការនៃយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិ និងអនុត្តរភាពផ្នែកនយោបាយជាសកលដែលប្រកាន់បក្សពួក ។[២៥] អំណាចបញ្ជូន ឬមិនបញ្ជូនសំណុំរឿង ចេញពីក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិអាចដោះស្រាយចំពោះភាពមន្ទិលសង្ស័យអំពីទំហំនៃឯករាជភាពចំពោះការចោទប្រកាន់ ដើម្បីវាយតម្លៃ និងកំណត់ពីការបញ្ជូនសំណុំរឿងទាំងនេះ ។[២៦] (ខ) ដាក់លក្ខខណ្ឌបែបនេះមានប្រភពចេញពីអ្វីដែលប្រទេសមហាអំណាចនៅក្នុងក្រុម

---

[២២] ស្ទួន កំណត់ចំណាំ មាត្រា ១៣(ខ) សូមកត់សម្គាល់ដែរថា រដ្ឋជាសមាជិក (មាត្រា ១៣(ខ), ១៤(១) និងព្រះរាជអាជ្ញា (មាត្រា ១៥(១) អាចបញ្ជូនរឿងឲ្យតុលាការព្រហ្មទណ្ឌអន្តរជាតិចាប់ផ្តើមប្រើប្រាស់យុត្តាធិការរបស់ខ្លួនបានដូចគ្នា ។

[២៣] ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ត្រូវបានផ្តល់អំណាចឲ្យតាមធម្មនុញ្ញអង្គការសហប្រជាជាតិ ជំពូកVII អង្គការសហប្រជាជាតិ, ធម្មនុញ្ញអង្គការសហប្រជាជាតិ, ២៤ តុលា ១៩៤៥, I UNTS XVI. លក្ខខណ្ឌតម្រូវឲ្យតុលាការព្រហ្មទណ្ឌអន្តរជាតិគោរពតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខ មានចែងនៅក្នុងលក្ខន្តិកៈទីក្រុងរ៉ូម, មាត្រា ១៦ ។

[២៤] សូមមើលជាទូទៅ David Scheffer, *The United States and the International Criminal Court*, ៩៣:១ AM. J. INT'L L., ១២ (១៩៩៩).

[២៥] FINDLAY, កំណត់ចំណាំខាងដើម ៣, ជំពូក ៣ ។

[២៦] សូមមើលទូទៅ Chris Gallavin, *Prosecutorial Discretion within the ICC: Under the Pressure of Justice*, ១៧:១ CRIM. L. FORUM, ៤៣ (២០០៦).

ប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ យល់ថាត្រឹមត្រូវ ដែលត្រូវបានស្តែងចេញឲ្យឃើញតាមរយៈដំណោះស្រាយរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ក្នុងការធ្វើឲ្យកងរក្សាសន្តិភាពនៅក្នុងប្រទេសអតីតយូហ្គោស្លាវី រួចផុតពីការកាត់ទោសដោយតុលាការព្រហ្មទណ្ឌអន្តរជាតិ ។[២៧] សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ដែលបានដាក់ឲ្យនៅក្រៅយុត្តាធិការរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ នូវកងរក្សាសន្តិភាពមកពីរដ្ឋមិនមែនសមាជិករបស់តុលាការនេះ ដែលមានវត្តមាននៅបូស្នៀ និងហឺហ្សេហ្គោវីណា (Herzegovina)[២៨] ត្រូវបានធ្វើឡើង ដើម្បីឆ្លើយតបនឹងការគំរាមកំហែងពីសហរដ្ឋអាមេរិក ក្នុងការវេតូការបន្តបេសកម្មសាជាថ្មីរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិនៅបូស្នៀ និងហឺហ្សេហ្គោវីណា ប្រសិនបើសេចក្តីសម្រេចនេះមិនត្រូវបានអនុម័ត ។[២៩] សេចក្តីសម្រេចស្រដៀងគ្នារបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ បានផ្តល់អភ័យឯកសិទ្ធិជូនដល់កងរក្សាសន្តិភាពនៅក្នុងជម្លោះ នៅប្រទេសលីបេរីយ៉ា ដែលដាក់ពង្រាយដើម្បីធានាសុវត្ថិភាពដល់បេសកកម្មមនុស្សធម៌នៅក្នុងប្រទេសនេះ និង រៀបចំសម្រាប់ឲ្យកងកម្លាំងអង្គការសហប្រជាជាតិនៅពេលអនាគតដែលមានភារកិច្ចថែរក្សាស្ថិរភាព ។[៣០] ភស្តុតាងកន្លងមកបង្ហាញឲ្យឃើញយ៉ាងច្បាស់ណាស់ថា ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ មានអំណាចសម្រេចថាតើគួរចាត់វិធានការ ឬមិនចាត់វិធានការណាមួយ ក្នុងការដាក់ឲ្យមានការទទួលខុសត្រូវចំពោះមុខតុលាការព្រហ្មទណ្ឌ

---

[២៧] សូមមើលទូទៅ Neha Jain, *A Separate Law for Peacekeepers: The Clash between the Security Council and the International Criminal Court*, ១៦:២ EURO. J. INT'L L. ២៣៩ (២០០៥).

[២៨] សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខលេខ I៤២២ ស្នើសុំតុលាការព្រហ្មទណ្ឌអន្តរជាតិឲ្យអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនតាមមាត្រា ១៦ ដើម្បីទប់ស្កាត់កុំឲ្យចាប់ផ្តើមស៊ើបអង្កេត ឬជំនុំជម្រះរឿងក្តីណាមួយទាក់ទងនឹងចំណាត់ការផ្សេងៗក្នុងប្រតិបត្តិការដែលអនុញ្ញាតដោយអង្គការសហប្រជាជាតិក្នុងរយៈពេល១២ខែ ។ រយៈពេលនេះត្រូវបានបន្តសាជាថ្មីម្តងហើយម្តងទៀត នៅក្នុងសេចក្តីសម្រេចលេខ I៤៨៧ ។ សូមមើល *United Nations Peacekeeping*, UN Doc. S/RES/I422 (2002); *United Nations Peacekeeping*, UN Doc. S/RES/I487 (2003).

[២៩] Jain, កំណត់ចំណាំខាងដើម ២៧ ។

[៣០] សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខ លេខ I៤៩៧ មានភាពរឹងមាំជាងសេចក្តីសម្រេច លេខ I៤២២ ដោយសារតែផ្តល់យុត្តាធិការផ្តាច់មុខ ក្នុងការចូលរួមរបស់រដ្ឋអធិបតេយ្យលើបុគ្គលនៃរដ្ឋនោះ ក្នុងរយៈពេលមិនដាក់លាក់មួយ ។ សូមមើល UN Doc. S/RES/១៤៩៧ (២០០៣) ។

អន្តរជាតិ តាមរយៈការអនុញ្ញាតឲ្យអ្នកដែលបំពេញកាតព្វកិច្ចអន្តរាគមន៍នៃអង្គការសហប្រជាជាតិទទួលបានអភ័យឯកសិទ្ធិសម្រាប់គោលបំណងបែបនេះ ។[៣១]

ឥទ្ធិពលរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិលើតុលាការមិនអចិន្ត្រៃយ៍ កាន់តែស្តែងឲ្យឃើញយ៉ាងច្បាស់ក្រឡែត ដោយសារតែតុលាការនេះ ត្រូវបានបង្កើតឡើងដោយដាក់ឲ្យនៅរណបនឹងក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ដែលខ្លួនអាចបញ្ឈប់តុលាការនេះបានគ្រប់ពេលវេលា ។ នៅចុងបញ្ចប់ ការសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិពីវិសាលភាពនៃការស៊ើបអង្កេត និងចោទប្រកាន់ និងពីសមត្ថភាពកំណត់យុត្តាធិការពេលវេលា និងបិទការជំនុំជម្រះក្តីរបស់តុលាការ (សម្រាប់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី និងរ៉្វាន់ដា ទាក់ទងនឹងសំណុំរឿងថ្មីៗគិតត្រឹមឆ្នាំ២០១២) មានន័យថា ការអនុវត្តទាំងអស់របស់ស្ថាប័នយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិ គឺសុទ្ធតែអាស្រ័យទៅលើឥទ្ធិពល[ដែលគ្របដណ្តប់លើស្ថាប័ននេះ] ។[៣២]

## ៤. ការមិនផ្តល់សច្ចាប័ន ក្រៅពីអចិន្ត្រៃយ៍ និងអត្ថប្រយោជន៍?

ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ បានអនុម័តសេចក្តីសម្រេចស្រដៀងគ្នាមួយដែលដូចគ្នាទៅនឹងសេចក្តីសម្រេចការពារកងកម្លាំងទ័ពនៅក្នុងជម្លោះអតីតយូហ្គោស្លាវី ការពារមន្ត្រីដែលមិនមែនជាជាតិស៊ូដង់នៅក្នុងប្រតិបត្តិការនៅដាហ្វ៊ួរ (ប្រតិបត្តិការណ៍ដែលអនុញ្ញាតដោយក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ និងសហគមន៍អាហ្វ្រិក) ។ សេចក្តីសម្រេចបានចែងថា បុគ្គលិកទាំងនោះ (ប្រសិនបើមាន) នឹងស្ថិតនៅក្រោមយុត្តាធិការរបស់ប្រទេសពួកគេទាំងស្រុង ហើយហេតុដូច្នេះ ទទួលបាននូវការការពារឲ្យរួចផុតពីការចោទប្រកាន់ដោយតុលាការព្រហ្មទណ្ឌអន្តរជាតិ ។[៣៣] ផ្ទុយទៅវិញ នៅក្នុងការអនុវត្តជាក់ស្តែង ការចោទប្រកាន់ដោយចោះៗដែលមានលក្ខណៈនយោបាយ និងដោយប្រភេទ

---

៣១ Megan Bastick, Karin Grimm & Rahel Kunz, *Sexual Violence in Armed Conflict: Global Overview and Implications for the Security Sector*, Geneva Centre for the Democratic Control of Armed Forces (២០០៧), អាចរកបាននៅលើគេហទំព័រ http://www.essex.ac.uk/armedcon/story_id/sexualviolence_conflict_full%5B1%5D.pdf.

៣២ សូមមើលទូទៅ Vesselin Popovski, *International Criminal Court: A Necessary Step Towards Global Justice*, ៣១:៤ SECURITY DIALOGUE ៤០៥ (២០០០).

៣៣ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិលេខ ១៥៩៣, UN Doc. S/RES/១៥៩៣ (២០០៥) ។ សូមមើល Gallavin, កំណត់ចំណាំខាងដើម **Error! Bookmark not defined.**

បទល្មើសដាក់លាក់ ព្រមទាំងដែនកំណត់ភ័ស្តុតាង ដែលគ្របដណ្តប់យុត្តាធិការរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិជាទូទៅ ប្រហែលជាអាចធ្វើឲ្យសេចក្តីសម្រេចទាំងនេះរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ មិនសូវចាំបាច់ទៅវិញ។ បើទោះបីជាដូច្នេះក៏ដោយ សេចក្តីសម្រេចទាំងនេះនៅតែតំណាងឲ្យគោលបំណងក្នុងការកម្រិតទំហំនៃយុត្តាធិការរបស់តុលាការអន្តរជាតិ តាមរបៀបមួយដែលបានបង្ហាញឲ្យឃើញនូវគោលបំណងសំខាន់ ដោយឥទ្ធិពលគ្របដណ្តប់ផ្នែកយោបាយនៃទំនាក់ទំនងអន្តរជាតិជាពិសេស យុទ្ធសាស្ត្រនៃការចរចា និងការដាក់លក្ខខណ្ឌ ដែលប្រកាន់យកដោយរដ្ឋសមាជិកដែលរួមទាំងសហរដ្ឋអាមេរិកផង ចំពោះការរួមចំណែកនៅក្នុងជំនួយផ្នែកមនុស្សធម៌ និងការរក្សាសន្តិភាពដោយសាររដ្ឋសមាជិកទាំងនោះព្យាយាមការពារបុគ្គលិករបស់ខ្លួនឲ្យរួចផុតពីការជំនុំជម្រះដោយតុលាការព្រហ្មទណ្ឌអន្តរជាតិ។ នៅក្នុងពេលអនាគត ការដោះដូរគ្នាខាងវិស័យសន្តិសុខ នៅឯក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ប្រហែលជាមិនត្រូវធ្វើឡើងដោយឥតលាក់លាម ឬដោយពិបាកនិយាយគ្នាឲ្យយល់នោះទេ ដោយសារអង្គការសហប្រជាជាតិបានងាកចេញពីការប្រើប្រាស់អន្តរាគមន៍យោធាដើម្បីរក្សាសន្តិភាព ទៅរកសេចក្តីសម្រេចខាងយុត្តិធម៌ដែលមានលក្ខណៈទូលំទូលាយជាងមុន។[៣៨]

ចំពោះចំណោទទាក់ទងទៅនឹងឋានៈរបស់ជនជាប់ចោទ នៅតុលាការព្រហ្មទណ្ឌអន្តរជាតិ និងតុលាការអចិន្ត្រៃយ៍ គឺអាស្រ័យទៅតាមរបៀបដែលជនជាប់ចោទត្រូវបានកំណត់អត្តសញ្ញាណ និងស្ថិតនៅក្រោមការស៊ើបអង្កេត និងចោទប្រកាន់។ នៅក្នុងស្ថាប័នយុត្តិធម៌ព្រហ្មទណ្ឌក្នុងស្រុក ការដាក់ឲ្យអនុវត្តរបស់ស្ថាប័នរៀបចំខាងប៉ូលីសដ៏ស្មុគស្មាញ មានន័យថា ជនសង្ស័យត្រូវឆ្លងកាត់ដំណើរការស៊ើបអង្កេតតាមបទដ្ឋានត្រឹមត្រូវ និងលម្អិត ទម្រាំឈានដល់ការចាប់ខ្លួន និងចោទប្រកាន់។ ទោះបីជាយ៉ាងណាក៏ដោយ នៅកម្រិតអន្តរជាតិផ្លូវឆ្ពោះទៅរកការកំណត់អត្តសញ្ញាណជនសង្ស័យ និងដំណើរការនីតិវិធី មិនសូវមានលក្ខណៈផ្លូវការទេ ហើយមិនអាចព្យាករណ៍បានទៀតផង ពីព្រោះមានការលំបាកខាងកិច្ចការនគរបាល (ដែលត្រូវពឹងផ្អែកទាំងស្រុងលើរដ្ឋសមាជិក និងជំនួយទៅវិញទៅមក) និងភាពគ្មានតឹងប្រទាញប្រទង់គ្នា ដែលទាក់ទងនឹងស្វ័យភាពនៃយុត្តាធិការដែលរារាំងកិច្ចសហប្រតិបត្តិការ។ ជនជាប់ចោទ អាចត្រូវបានរដ្ឋសមាជិកចាប់បញ្ជូនទៅឲ្យតុលាការព្រហ្មទណ្ឌអន្តរជាតិ ដោយក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិជាអ្នកផ្តល់អត្តសញ្ញាណជូន ឬព្រះរាជអាជ្ញាឯករាជ្យអាចចេញដីកាចាប់ខ្លួនដែលតម្រូវឲ្យជនជាប់ចោទបង្ហាញខ្លួន សម្រាប់ការស៊ើបអង្កេត និងចោទប្រកាន់។ ប៉ុន្តែ ដូចមាន

---

៣៨ John Boonstra, *Tension Between Peace and Justice*, UN DISPATCH, 28 កុម្ភៈ 2008, នៅគេហទំព័រ http://www.undispatch.com/tension-between-peace-and-justice.

ឧទាហរណ៍ថ្មីៗជាគំរូស្រាប់ ប្រសិនជនជាប់ចោទអាចប្រើប្រាស់ឋានៈនយោបាយរបស់ខ្លួន ឬអំណាចក្នុងស្រុក និងតំបន់របស់ខ្លួន ប្រឆាំងនឹងការចេញដីកាចោទប្រកាន់កម្រិតជាតិ និងអន្តរជាតិនោះ ការធ្វើឲ្យជនជាប់ចោទបង្ហាញខ្លួននៅចំពោះមុខតុលាការអន្តរជាតិបែបនេះ គឺពិតជាជួបភាពស្មុគស្មាញកាន់តែខ្លាំងឡើងៗ និងមានបញ្ហាជាច្រើន ។[៣៥]

ហេតុផលនៅពីក្រោយការបញ្ជូនសំណុំរឿង ដោយក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ អាចនឹងធ្វើឲ្យយើងដឹងផងដែរ នៅពេលគិតដល់ផលប្រយោជន៍ជាតិ និង សម្ព័ន្ធភាពនៃទំនាក់ទំនងអន្តរជាតិ ។ ទោះបីជាបដិសេធមិនទទួលយកយុត្តាធិការរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិលើប្រជាពលរដ្ឋខ្លួនក៏ដោយ សហរដ្ឋអាមេរិកបានជំរុញក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិឲ្យបញ្ជូនប្រធានាធិបតីស៊ូដង់មកឲ្យតុលាការព្រហ្មទណ្ឌអន្តរជាតិកាត់ទោសដែរ ។ ជាលទ្ធផល តុលាការព្រហ្មទណ្ឌអន្តរជាតិ បានចេញដីកា ចោទប្រកាន់លើប្រធានាធិបតី ស៊ូដង់ គឺលោក អូម៉ា បាសៀ តាំងតែពីឆ្នាំ ២០០៥មកម្ល៉េះ ពីបទចូលរួមក្នុងឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅដាហ្វ័រ ។[៣៦] ប៉ុន្តែ ក្នុងខែកក្កដា ឆ្នាំ២០០៨ ក្នុងជំនួបប្រមុខដឹកនាំរដ្ឋនៅអាហ្វ្រិក សហគមន៍អាហ្វ្រិកបានសម្រេចសុំឲ្យតុលាការព្រហ្មទណ្ឌអន្តរជាតិផ្អាករាល់ចំណាត់ការណ៍ផ្សេងៗ ហើយជំនួសមកវិញដោយការអនុញ្ញាតឲ្យបើកការស៊ើបអង្កេតដែលដឹកនាំដោយអាហ្វ្រិកវិញ ។ ចាប់តាំងពីពេលនោះមក បណ្តារដ្ឋនៅអាហ្វ្រិក ដូចជា ឆាដ គេនយ៉ា ជីបូទី (Djibouti) និងម៉ាឡាវី បដិសេធ មិនគោរពកាតព្វកិច្ចរបស់ខ្លួនដែលជារដ្ឋសមាជិកនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ ដូចជាសំណើសុំឲ្យចាប់ខ្លួន បាសៀ ជាដើម នៅពេលបាសៀកំពុងមានវត្តមានក្នុងប្រទេសទាំងនោះ ។ ចៅក្រមនៃតុលាការ ព្រហ្មទណ្ឌអន្តរជាតិបានរាយការណ៍ពីប្រទេសទាំងនេះជូនក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ និងសន្និបាតនៃរដ្ឋសមាជិករបស់តុលាការព្រហ្មទណ្ឌអន្តរជាតិដែរ ប៉ុន្តែគ្មានឃើញមានវិធានការណាមួយត្រូវបានធ្វើឡើងនៅឡើយទេ ។[៣៧] កាលពីខែធ្នូ ឆ្នាំ២០១១កន្លងទៅ តុលាការព្រហ្មទណ្ឌអន្តរជាតិបានក្រើនរំឭក ម៉ាឡាវី ពីសំណុំរឿង

---

[៣៥] សូមមើល Bernard Momanyi, *Kenya Seeks Delay to ICC Trials*, ACT Issue 366, IWPR, Oct. 17, 2013 អាចរកបាននៅលើគេហទំព័រ http://iwpr.net/report-news/kenya-seeks-delay-icc-trials

[៣៦] ប្រធានាធិបតី Bashir ត្រូវបានបញ្ជូនទៅតុលាកាព្រហ្មទណ្ឌអន្តរជាតិ ដោយក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ដោយសារ Sudan មិនមែនជារដ្ឋសមាជិករបស់តុលាការនេះ ។

[៣៧] ចៅក្រមតុលាការព្រហ្មទណ្ឌអន្តរជាតិច្រានចោលភាពស្របច្បាប់នៃសេចក្តីសម្រេចរបស់សហគមន៍អាហ្វ្រិក លើករណី *Bashir ដោយបញ្ជូនការមិនគោរពតាមរបស់ម៉ាឡាវីទៅក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ*, SUDAN TRIBUNE Dec. 13, 2011, នៅគេហទំព័រ http://www.sudantribune.com/spip.php?iframe&page=imprimable&id_article=40980.

ដីកាចាប់ខ្លួន ដែលតុលាការយុត្តិធម៌អន្តរជាតិបានបញ្ជាក់យ៉ាងច្បាស់ថា គោលការណ៍នៅក្នុងច្បាប់អន្តរជាតិដែលផ្តល់អភ័យឯកសិទ្ធិដល់អតីតប្រមុខរដ្ឋ និងប្រមុខរដ្ឋក្នុងតំណែង មិនអាចរារាំងមិនឲ្យតុលាការអន្តរជាតិចោទប្រកាន់លើរឿងក្តីព្រហ្មទណ្ឌបានឡើយ ទោះបីជារដ្ឋដែលត្រូវចោទប្រកាន់ថាបានប្រព្រឹត្តបទល្មើស ជាសមាជិក ឬមិនមែនជាសមាជិករបស់តុលាការព្រហ្មទណ្ឌអន្តរជាតិក៏ដោយ ។[៣៨]

## ៥. ផលប្រយោជន៍ជាតិ និង ផលប្រយោជន៍សកលៈ ដំណើររឿងនៃកាលានុវត្តន៍នយោបាយ

ដូចដែលបានបញ្ជាក់ពីខាងលើ នៅពេលដែលបទល្មើសស្ថិតនៅក្រោមយុត្តាធិការរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ត្រូវបានប្រព្រឹត្តឡើងទៅនៅក្នុងដែនដី ឬដោយរដ្ឋជាសមាជិក រដ្ឋជាសមាជិកនោះអាចបញ្ជូនជនជាប់ចោទឲ្យតុលាការព្រហ្មទណ្ឌអន្តរជាតិកាត់ទោសបាន[៣៩] ឬព្រះរាជអាជ្ញាអាចផ្តួចផ្តើមការស៊ើបអង្កេតលើឧក្រិដ្ឋកម្មនោះដោយខ្លួនឯង ដែលអាចចាប់ផ្តើមបានក្នុងករណីដែលអង្គបុរេជំនុំជម្រះផ្តល់ការអនុញ្ញាត ។[៤០] លើសពីនេះទៅទៀត ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ អាចបញ្ជូនរឿងក្តីទៅតុលាការព្រហ្មទណ្ឌអន្តរជាតិបាន[៤១] ហើយរដ្ឋដែលមិនមែនជាសមាជិក អាចទទួលយកយុត្តាធិការរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ តាមសំណុំរឿងនីមួយៗ ។[៤២] បញ្ហាជាមូលដ្ឋានមួយដែលនាំឲ្យរដ្ឋទាំងនោះមិនព្រមទទួលយកយុត្តាធិការរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ គឺថា ព្រះរាជអាជ្ញាឯករាជ្យអាចប្រើប្រាស់ឆន្ទានុសិទ្ធិរបស់ខ្លួនធ្វើការចោទប្រកាន់លើបុគ្គលិកយោធាណាម្នាក់ ដែលចូលរួមក្នុងបេសកម្មថែរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ ឬក្នុងអន្តរាគមន៍យោធា ដែលធ្វើឡើងដើម្បីធានានូវផលប្រយោជន៍ក្នុងតំបន់ និងអន្តរជាតិ ។

---

[៣៨] Prosecutor v. Omar Hassan Ahmad Al Bashir, សំណុំរឿងលេខ. ICC-02/05-01/09 (PTC I, ១២ ធ្នូ ២០១១); សំណុំរឿងទាក់ទងនឹងដីកាចាប់ខ្លួន ១១ មេសា ២០០០ (Democratic Republic of the Congo v. Belgium), សាលក្រម, ២០០២ I.C.J. ៣ ( ១៤ កុម្ភៈ ២០០២) ។

[៣៩] លក្ខន្តិកៈទីក្រុងរ៉ូម កំណត់ចំណាំខាងដើម ២ មាត្រា ១៣(ក), ១៤ ។

[៤០] ស្ដូន មាត្រា ១៣(គ), ១៥ ។

[៤១] ស្ដូន, មាត្រា ១៣(ខ); ធម្មនុញ្ញអង្គការសហប្រជាជាតិ, ជំពូក VII ។

[៤២] លក្ខន្តិកៈទីក្រុងរ៉ូម កំណត់ចំណាំខាងដើម ២, មាត្រា ១២(៣) ។

ពិតប្រាកដណាស់ គឺសហរដ្ឋអាមេរិកតែម្តងដែលមានវត្តមានច្រើនជាងគេនៅក្នុងតំបន់ទាំងនេះ ។ ក្រោមរដ្ឋការរបស់លោកប្រធានាធិបតី ប៊ូស មិនត្រឹមតែមិនមែនជារដ្ឋភាគីនៃលក្ខន្តិកៈទីក្រុងរ៉ូម ប៉ុណ្ណោះទេ សហរដ្ឋអាមេរិក ថែមទាំងបានគៀងគរឲ្យមានកិច្ចព្រមព្រៀងទ្វេភាគីជាច្រើន ដែលតម្រូវឲ្យរដ្ឋហត្ថលេខីសន្យាមិនប្រគល់ពលរដ្ឋ ឬបុគ្គលិកសហរដ្ឋអាមេរិក ឲ្យតុលាការព្រហ្មទណ្ឌអន្តរជាតិកាត់ទោស ហើយតាមរយៈនេះ បានដាក់កំហិតលើយុត្តាធិការរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ និងផ្តល់ការការពារដល់កងយោធាសហរដ្ឋអាមេរិក ។[៤៣] សហរដ្ឋអាមេរិក ព្យាយាមសម្រេចកិច្ចព្រមព្រៀងទាំងអស់នេះ ដើម្បីជួយឲ្យខ្លួនឯងរួចផុតពីយុត្តាធិការរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ដែលចែងក្នុងមាត្រា៩៨(២) ក្នុងលក្ខន្តិកៈទីក្រុងរ៉ូមថា តុលាការព្រហ្មទណ្ឌអន្តរជាតិ "មិនអាចធ្វើសំណើសុំបញ្ជូនខ្លួនណាមួយ ដែលតម្រូវឲ្យរដ្ឋអនុវត្តនោះ ធ្វើផ្ទុយពីកាតព្វកិច្ចរបស់ខ្លួន ក្រោមកិច្ចព្រមព្រៀងអន្តរជាតិបានទេ ។ យោងទៅតាមកិច្ចព្រមព្រៀងនោះ ចាំបាច់ត្រូវមានការយល់ពីរដ្ឋដែលត្រូវបញ្ជូនបុគ្គលនៃរដ្ឋនោះទៅតុលាការ និងមានការយល់ព្រមពីរដ្ឋដែលត្រូវបញ្ជូនជាមុន ទើបតុលាការអាចទទួលបានកិច្ចសហប្រតិបត្តិការ ។[៤៤] កិច្ចព្រមព្រៀងទាំងនេះត្រូវបានពង្រឹងឲ្យកាន់តែរឹងមាំថែមទៀតតាមរយៈការផ្តល់នូវជំនួយផ្នែកយោធា និងទម្រង់ផ្សេងទៀតនៃជំនួយហិរញ្ញវត្ថុរបស់សហរដ្ឋអាមេរិក ព្រមទាំងការគំរាមដកជំនួយយោធាពីរដ្ឋទទួលជំនួយណា ដែលបដិសេធមិនចុះហត្ថលេខាលើកិច្ចព្រមព្រៀងមិនបញ្ជូនខ្លួនទៅតុលាការព្រហ្មទណ្ឌអន្តរជាតិនេះ ។[៤៥]

ដោយឡែក ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិក៏បានសម្តែងក្តីព្រួយបារម្ភអំពីការការពាររដ្ឋមួយចំនួនដែលចូលរួមក្នុងប្រតិបត្តិការថែរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ ។ ចំណុចស្នូលនៃក្តីព្រួយបារម្ភអំពីស្ព័យភាពនិងការការពារបុគ្គលិកយោធាគឺការព្រួយបារម្ភដែលថា ព្រះរាជអាជ្ញា

---

[៤៣] សូមមើលទូទៅScheffer, កំណត់ចំណាំខាងដើម ២៣; Markus Benzing, *US Bilateral Non-Surrender Agreements* និងមាត្រា ៩៨ នៃ *the Statute of the International Criminal Court: An Exercise in the Law of Treaties*, 8:1 MAX PLANCK YEARBOOK OF UN LAW 181, 181-236 (2004), អាចរកបាននៅលើគេហទំព័រ http://www.mpil.de/files/pdf1/mpunyb_benzing_8.pdf; Judith G. Kelley, *Who Keeps International Commitments and Why? The International Criminal Court and Bilateral Non-surrender Agreements*, 3:101 AM. POLI SCI REV. 573, 573-89 (2007), *available at* http://papers.ssrn.com/sol3/papers.cfm?abstract_id=943711.

[៤៤] លក្ខន្តិកៈទីក្រុងរ៉ូម កំណត់ចំណាំខាងដើម ២, មាត្រា៩៨(២)

[៤៥] សូមមើល Kelley, កំណត់ចំណាំខាងដើម ៤១, ត្រង់ទំព័រ ៥៧៣ ។ ចូរកំណត់ចំណាំ ទោះបីជាយ៉ាងណាក៏ដោយ ដោយសារតែក្តីកង្វល់ផ្នែកសន្តិសុខ សហរដ្ឋអាមេរិក មិនបានដកជំនួយយោធាពីរដ្ឋទាំងអស់នោះ ដែលបដិសេធមិនចុះហត្ថលេខាលើកិច្ចព្រមព្រៀងមិនបញ្ជូនពលរដ្ឋអាមេរិកទៅឲ្យតុលាការព្រហ្មទណ្ឌអន្តរជាតិកាត់ទោស ។

ឯករាជ្យនឹងចាត់វិធានការប្រឆាំងទៅនឹងរដ្ឋដែលមានអំណាច ដោយពុំគិតដល់ផលប្រយោជន៍នយោបាយរបស់សហប្រជាជាតិនៅក្នុងអន្តរាគមន៍យោធា ។

តាមរយៈការពិភាក្សាខាងលើ មហាអំណាចដែលត្រួតត្រាពិភពលោក ចាត់ទុកយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិជារឿងបន្ទាប់បន្សំ បើប្រៀបធៀបនឹងផលប្រយោជន៍ជាតិរបស់ខ្លួន ហើយនេះត្រូវបានមើលឃើញមិនត្រឹមតែនៅក្នុងអំណះអំណាងអំពីស្វយ័តភាពរបស់រដ្ឋទាំងអស់នោះដែលបដិសេធមិនទទួលយកយុត្តាធិការរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិប៉ុណ្ណោះទេ ។[៤៦] ដូច្នេះ សម្ពាធត្រូវធ្លាក់ទៅលើសហគមន៍អង្គការអន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាល ដែលត្រូវរួមចំណែកយ៉ាងពិតប្រាកដចំពោះយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិ ឲ្យហួសពីការព្រំដែនកំហិតនៃហេតុផលក្នុងស្រុក និងតំបន់ ។[៤៧] បញ្ហានេះធ្លាប់កើតមានឡើងរួចមកហើយ គឺការពឹងផ្អែកជាបន្តបន្ទាប់ និងម្តងម្កាល របស់ព្រះរាជអាជ្ញាតុលាការព្រហ្មទណ្ឌអន្តរជាតិ លើការប្រមូលព័ត៌មាននៅហ្នឹងកន្លែងរបស់អង្គការមិនមែនរដ្ឋាភិបាល និងអន្តរាគមន៍ជួយសម្របសម្រួលដល់ការកំណត់អត្តសញ្ញាណសាក្សី និងការជួយផ្តល់សក្ខីកម្ម ។[៤៨] ចាប់តាំងពីការបង្កើតតុលាការព្រហ្មទណ្ឌអន្តរជាតិ នៅឯសន្និសីទទីក្រុងរ៉ូម «ទំនាក់ទំនង រវាងតុលាការព្រហ្មទណ្ឌអន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាលមានភាពជិតស្និទ្ធ រឹងមាំ និងសំខាន់ ចំពោះតុលាការព្រហ្មទណ្ឌអន្តរជាតិ ជាងទំនាក់ទំនងស្រដៀងគ្នារវាងអង្គការក្រៅរដ្ឋាភិបាល និងអង្គការអន្តរជាតិនានា» ដែលបញ្ហាជាច្រើនអាចកើតមាន ។[៤៩]

---

[៤៦] សូមមើលទូទៅ JASON RALPH, DEFENDING THE SOCIETY OF STATES: WHY AMERICA OPPOSES THE INTERNATIONAL CRIMINAL COURT AND ITS VISION OF WORLD SOCIETY (New York: Oxford University Press ២០០៧).

[៤៧] សូមមើល the International Center for Transitional Justice គេហទំព័រ, http://ictj.org/about

[៤៨] មាត្រា៥៤(៣)(ក) នៃលក្ខន្តិកៈទីក្រុងរ៉ូម ផ្តល់អំណាចឲ្យព្រះរាជអាជ្ញាស្វែងរកកិច្ចសហប្រតិបត្តិការពីបណ្តារដ្ឋ ឬអង្គការអន្តររដ្ឋាភិបាលនានា ឬអាចស្វែងរកការចាត់ចែងណាមួយ ស្របតាមសមត្ថកិច្ច ឬអាណត្តិរៀងៗខ្លួន ។ លក្ខន្តិកៈទីក្រុងរ៉ូម, កំណត់ចំណាំលេខ ២ ខាងលើ ។

[៤៩] សូមមើលទូទៅ BENJAMIN SCHIFF, BUILDING THE INTERNATIONAL CRIMINAL COURT (Cambridge University Press 2008). សម្រាប់ការពិភាក្សាអំពីផលវិបាកជាបញ្ហានៃភាពនៅក្រោមចំណុះសម្រាប់សមិទ្ធិផលនៃការទទួលបានសក្ខីកម្មរបស់សាក្សី ប្រកបដោយភាពទៀងត្រង់ សូមមើលទូទៅ Mark Findlay & Sylvia Ngane, *The Sham of the Moral Court: Testimony Sold as the Spoils of War*, 1:1 GLOBAL J. COMP. L 73 (2013).

ការផ្ដើមយុត្តិកម្មលើសេចក្ដីសន្និដ្ឋានដែលថា ស្ថាប័នយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិ គឺមានលក្ខណៈនយោបាយ ទាំងក្នុងការបង្កើត ទាំងការចាប់ផ្ដើមសកម្មភាព និងការច្រានចោលមិនចូលជាសមាជិក រួមមាន ៖

- ហេតុផលសម្អាងដែលគ្រប់គ្នាជាធម្មតាបាននិយាយដល់ ដូចជា ការបញ្ចប់និទណ្ឌភាព បានបំភាន់ភ្នែកហេតុផលពិតប្រាកដដែលមិនសូវជាសប្បុរស ។ ការបំភាន់ភ្នែកនេះ ស្ដែងឲ្យឃើញតាមរយៈការចោទប្រកាន់ដោយរើសមុខ ធ្វើឡើងក្នុងនាមស្ថាប័នយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិ ។ ការចោទប្រកាន់បែបនេះ បានលេចឡើងយ៉ាងច្បាស់តាំងពីពេលដំបូងៗ នៅក្នុងយុគសម័យបច្ចុប្បន្ននៃយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិ ។ ឧទាហរណ៍ នៅក្នុងការកាត់ទោសឧក្រិដ្ឋកម្មសង្គ្រាមនៅតូក្យូ អធិរាជហ៊ីរ៉ូហ៊ីតុ ដែលត្រូវគេស្គាល់ថា ជាអ្នកជំរុញពីខាងក្រោយនៃការប្រព្រឹត្តឧក្រិដ្ឋកម្មដ៏សាហាវយង់ឃ្នង បែរជាមិនត្រូវបានចោទប្រកាន់ទោសទៅវិញ ពីព្រោះខ្លាចក្រែងនាំឲ្យមានការពន្យារពេលបញ្ចប់សង្គ្រាមនៅប៉ាស៊ីហ្វិក ។[៥០]
- ការពិនិត្យពិច័យល្អិតល្អន់ជុំវិញហេតុផលសប្បុរសធម៌ ទាក់ទងនឹងមូលហេតុ ដែលរដ្ឋនឹងបង្កើតស្ថាប័នជំនុំជម្រះទោសថ្នាក់ជាតិ និងអន្តរជាតិ ដែលប្រហែលជាអាចវិលមកប្រឆាំងនឹងប្រទេសខ្លួនឯងវិញ ។ ឧទាហរណ៍ សហរដ្ឋអាមេរិក បានដកខ្លួនចេញពីការចូលរួមជាមួយតុលាការព្រហ្មទណ្ឌអន្តរជាតិ មួយផ្នែក គឺដោយសារតែខ្លាចក្រែងតុលាការព្រហ្មទណ្ឌអន្តរជាតិធ្វើតាមតួនាទី និងតាមផលប្រយោជន៍របស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ហើយដោយសារតែការអនុវត្តផ្ទុយនៃអំណាចវេតូរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ដោយមហាអំណាចដែលប្រកួតប្រជែងគ្នា[៥១] ផលប្រយោជន៍របស់សហរដ្ឋអាមេរិក អាចនឹងមិនសមស្របតាមដំណោះស្រាយរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ជានិច្ចកាលនោះទេ ។ ជ្រុងម្ខាងទៀតនៃក្ដីកង្វល់របស់អាមេរិក គឺថា ក្នុងនាមជាសមាជិកអចិន្ត្រៃយ៍នៃក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ សហរដ្ឋអាមេរិក យ៉ាងហោចណាស់ អាចអនុវត្តសិទ្ធិវេតូដើម្បីការពារផលប្រយោជន៍របស់ខ្លួនទល់នឹងដីកាចោទប្រកាន់របស់តុលាការបាន ។ ទោះបីជាមានភាពលម្អៀង

---

[៥០] សូមមើលទូទៅ ARNOLD BRACKMAN, THE OTHER NUREMBERG: THE UNTOLD STORY OF THE TOKYO WAR CRIMES TRIALS (1987).

[៥១] ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិប្រតិបត្តិការតាមសមត្ថភាពដោយអនុញ្ញាតឲ្យរដ្ឋជាសមាជិកអចិន្ត្រៃយ៍វេតូប្រឆាំងនឹងសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សា ។ ការធ្វើរបៀបនេះ ពេលខ្លះនាំភាពមិនឈ្នះមិនចាញ់រវាងសមាជិកទាំងនោះដែលព្យាយាមប្រើប្រាស់អំណាចបញ្ចូន និងសមាជិកដែលប្រឆាំងនឹងការបញ្ចូន ។

ខ្លះៗនៃ(ខ)ដាក់លក្ខខណ្ឌក៏ដោយ យើងអាចនិយាយបានថា រដ្ឋជាច្រើនដែលគាំទ្រតុលាការព្រហ្មទណ្ឌអន្តរជាតិ ធ្វើបែបនេះដោយសារមានជំនឿថា តុលាការព្រហ្មទណ្ឌអន្តរជាតិនឹងមិនប្រឆាំងផលប្រយោជន៍របស់មហាអំណាចទាល់តែសោះ ។

ចំពោះការប្រើប្រាស់ហេតុផលទាក់ទងនឹងសារជាតិនយោបាយរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ និង(ខ)ដាក់លក្ខខណ្ឌរបស់មហាប្រទេសអំណាច និងការលើកឡើងនូវហេតុផលស្រដៀងៗគ្នាមួយចំនួនអំពីមូលហេតុដែលប្រជាជាតិជាច្រើននៅតំបន់អាស៊ីប៉ាស៊ីហ្វិក ស្ទាក់ស្ទើរទទួលយកនូវយុត្តាធិការរបស់តុលាការនេះ ។ ខ្ញុំសូមផ្តល់ជាគំនិតខាងក្រោមថា មានលក្ខខណ្ឌប្រវត្តិសាស្រ្ត វប្បធម៌ នរវិទ្យា និងសង្គម ដែលគួរឲ្យជឿច្រើនទៀត ដែលអាចផ្តល់ការពន្យល់មួយគួរឲ្យជឿបានកាន់តែខ្លាំងថែមទៀត ។

## ៦. មូលហេតុនៃការមិនផ្តល់សច្ចាប័ននៅក្នុងតំបន់ : ភាពរសើបរបស់រដ្ឋ និង ភាពស្ទាក់ស្ទើរនៅក្នុងតំបន់

មុខមាត់យុត្តិធម៌ព្រហ្មទណ្ឌនៅទូទាំងអាស៊ី និងប៉ាស៊ីហ្វិក ត្រូវកំណត់ដោយ ៖

- ប្រពៃណីអាណានិគមអឺរ៉ុប
- ឥទ្ធិពលវប្បធម៌របស់អ្នកស្រុក និងអន្តោប្រវេសន៍
- សម្ពាធនៃសេដ្ឋកិច្ចពាណិជ្ជកម្ម និងសេដ្ឋកិច្ចបន្ទាប់បន្សំ
- ជម្លោះរវាងសាសនាដែលមានស្រាប់ និងសាសនាដែលនាំចូល
- កាតព្វកិច្ចនៃភាពស្មោះត្រង់ចំពោះក្រុម និងគុណធម៌នៃការគោរពឪពុកម្តាយ-បុព្វបុរស និង
- ការរីកលូតលាស់ឥតឈប់ឈរនៃទំនើបកម្ម និងសម្ភារនិយម ។[៥៧]

ឥទ្ធិពលនៃកម្លាំងទាំងនេះ មិនស្របគ្នា និងមិនទៀងទាត់ទេ ។ អ្វីដែលនៅតែទៀងទាត់ គឺភាពមិនចុះសម្រុងគ្នា រវាងស្ថាប័នយុត្តិធម៌ព្រហ្មទណ្ឌដែលផ្អែកទៅលើរដ្ឋ និង ដំណើរការនៃការសម្រេចចិត្ត និងដោះស្រាយជម្លោះតាមប្រពៃណី ។ ការខិតខំប្រឹងប្រែងដើម្បីគ្របពីលើបញ្ហាយុត្តិធម៌ជាសកល

---

[៥៧] សូមមើលទូទៅ Mark Findlay, *Decolonising Restoration and Justice: Restoration in Transitional Cultures, in* RESTORATIVE JUSTICE: PHILOSOPHY TO PRACTICE 185 (Heather Strang & John Braithwaite, eds., William Morrow & Co. 2000).

ដោយកញ្ចប់មួយដែល«មួយត្រូវទាំងអស់» ហើយវាមិនលំបាកនឹងមើលទំហំនៃការប្រឆាំងដែលនឹងរីកធំឡើងនោះទេ ។[៥៣]

ការកំណត់មូលហេតុនៃភាពរឹងទទឹងមិនផ្តល់សច្ចាបន័ លើយន្តការតុលាការយុត្តិធម៌អន្តរជាតិពីថ្នាក់តំបន់ដល់ថ្នាក់សកល ទូទាំងអាស៊ី និងប៉ាស៊ីហ្វិក គឺសុទ្ធតែមានហានិភ័យចំពោះការសង្កត់ធ្ងន់ហួសហេតុពេកអំពីភាពខុសគ្នានៃវប្បធម៌ និងនយោបាយ ខណៈពេលដែលកំពុងមានការស្វះស្វែងរកគោលគំនិតជាសកល ដោយមិនគិតអំពីភាពខុសគ្នានៃយុត្តាធិការជាក់លាក់ ។ មធ្យោបាយមួយដើម្បីជៀសវាងការធ្វើបែបនេះ គឺត្រូវបែងចែងជាប្រភេទៗនៃភាពស្ទាក់ស្ទើរក្នុងការទទួលស្គាល់ឥទ្ធិពលសំខាន់ទៅលើយុត្តិធម៌ព្រហ្មទណ្ឌទំនើបនៅក្នុងតំបន់ ។ ដើម្បីផ្គុំប្រភេទផ្សេងៗចូលគ្នា ចាំបាច់ត្រូវមានការឆ្លុះបញ្ចាំងឲ្យឃើញ ទោះបីជាមានលក្ខណៈសង្ខេបក៏ដោយ អំពីភាពមិនទាក់ទងគ្នារវាងដំណើរការយុត្តិធម៌ផ្លូវការ (ដូចដែលបានបង្ហាញនៅតុលាការព្រហ្មទណ្ឌអន្តរជាតិ) និង របៀបដោះស្រាយជម្លោះ ដែលមាននៅក្នុងស្រុក ឬរបៀបដោះស្រាយជម្លោះតាំងពីយូរលង់មកក្នុងវប្បធម៌នៃតំបន់នេះ ។ ភាពមិនស្របគ្នាលើវិធីដែលយុត្តិធម៌ត្រូវបានកំណត់ វិនិច្ឆ័យ និងដោះស្រាយនេះ ប្រហែលជាអាចសមល្មមនឹងដឹងអំពីមូលហេតុដែលរដ្ឋ និងវប្បធម៌ខ្លះ មិនចាប់អារម្មណ៍លើយន្តការជាសកល ជាពិសេសនៅពេលដែលយន្តការនោះមានលក្ខណៈចំឡែកខ្លាំងពេកនឹងបទពិសោធន៍របស់ខ្លួន ។

## ៦.១. ភាពឆាក់ឆងគ្នា?

នៅតំបន់ប៉ាស៊ីហ្វិក ត្រូវបានដឹងថា មានវិបត្តិសកលជាច្រើនបានកើតឡើង ហើយច្រើនជាងអ្វីដែលបានបង្ហាញនៅក្រោមយុត្តាធិការរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ដែលធ្វើឲ្យប្រទេសតូចៗដែលមានសមត្ថភាពមានកំណត់ ត្រូវផ្តល់អាទិភាពចម្បងសម្រាប់ដោះស្រាយមុន ព្រោះសមត្ថភាពរបស់ខ្លួនមានកំណត់នៅក្នុងការចូលរួមជាលក្ខណៈអន្តរជាតិ ។ រដ្ឋដែលជាកោះតូចៗនៅប៉ាស៊ីហ្វិក បានកំណត់ការកើនឡើងនៃសីតុណ្ហភាពពិភពលោក និងការឡើងនៃកម្រិតកម្ពស់ទឹកសមុទ្រ ថាជាបញ្ហាចម្បងសម្រាប់«យុត្តិធម៌»សង្គម ដែលប្រទេសទាំងនោះស្នើសុំឲ្យចាត់វិធានការជាបន្ទាន់ដោយស្ថាប័នផ្សេងៗនៅក្នុងសហគមន៍អន្តរជាតិ ។ មេដឹកនាំនយោបាយ និងប្រជាជននៅក្នុងសមុទ្រប៉ាស៊ីហ្វិក អល់អែកដែលថា ការបំផ្លិចបំផ្លាញបរិស្ថានដែលគំរាមកំហែងភាពគ្មានទីជម្រករបស់ប្រជាជាតិ និងវប្បធម៌ផ្សេងៗ

---

[៥៣] PEACE OPERATIONS AND ORGANIZED CRIME: ENEMIES OR ALLIES? (James Cockayne & Adam Lupel eds., Routledge 2011).

ពុំត្រូវបានចាត់ទុកថាជា«ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ» ឬថា ភាពគ្មានទីជម្រករស់នៅ ពុំមែនជា «អំពើប្រល័យពូជសាសន៍» ផ្នែកវប្បធម៌ទេ ។[៥៤]

នៅក្នុងតំបន់ដែលអ៊ីៗ«ពឹងផ្អែកទៅលើជំនួយ» ដើម្បីគាំទ្ររបបនយោបាយ និងសេដ្ឋកិច្ចទន់ខ្សោយ ទំនាក់ទំនងផ្សេងៗឲ្យលើសពីរដ្ឋប្រជាជាតិ ត្រូវបានជំរុញតាមរយៈទ្វេភាគីនិយម ជាជាងពហុភាគីនិយម ។ អន្តរជាតូបនីយកម្មគឺមិនមែនប្រាកដថាជាការបំពេញបន្ថែមលើសហប្រតិបត្តិការសេដ្ឋកិច្ចដែលផ្តល់ផលប្រយោជន៍ដល់ពិភពលោកខាងជើងផ្នែកពាណិជ្ជកម្ម និងធនធានឡើយ ប៉ុន្តែបែរជាដាក់កាតព្វកិច្ចលើពិភពលោកខាងត្បូង តាមរយៈទាសភាពខាងបំណុល និង ការពឹងផ្អែកទៅលើជំនួយ ។

បញ្ហាពាក់ព័ន្ធផ្សេងទៀត ជាពិសេស ដោយសារវាទាក់ទងនឹងរដ្ឋជាកោះតូចៗនៅសមុទ្រប៉ាស៊ីហ្វិក និងទាក់ទងនឹងរដ្ឋនៅក្រោមយុត្តាធិការអាស៊ី ដែលក្រីក្រ ឬកំពុងរីកលូតលាស់ គឺបញ្ហាសមត្ថភាពនីតិបញ្ញត្តិនៅមានកម្រិត ។ រដ្ឋាភិបាលជាច្រើនមានសេវានីតិបញ្ញត្តិចង្អៀតចង្អល់ដែល នៅពេលនិយាយអំពីការផ្តល់សច្ចាប័នទៅលើអនុសញ្ញារបស់អង្គការសហប្រជាជាតិ តម្រូវឲ្យមានការឲ្យហេតុផលសម្រាប់ការចូលរួមជាលក្ខណៈអន្តរជាតិ ដើម្បីប្រៀបធៀបទៅនឹងអាទិភាពផ្សេងទៀត របស់រដ្ឋ ។

អ្នកគាំទ្រឲ្យមានការផ្តល់សច្ចាប័នលើតុលាការព្រហ្មទណ្ឌអន្តរជាតិ ចាំបាច់ត្រូវបង្ហាញឲ្យឃើញនូវគុណប្រយោជន៍នៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌជាសកល ដល់រដ្ឋតូចៗទាំងនោះ ជាជាងជាបន្ទុករបស់រដ្ឋតូចៗទាំងនោះទៅវិញ ។

## ៦.២. ការឈានទៅដល់កម្រិតសកល

«កត្តាដែលធ្វើឲ្យអស់ជំនឿ»នៃឥទ្ធិពលខុសៗគ្នារបស់ប្រទេសមហាអំណាច (ខាងសេដ្ឋកិច្ច និងការទូត) នៅក្នុងតំបន់ ជាធម្មតា ត្រូវបានតំណាងឲ្យដោយអង្គការ និងភ្នាក់ងារអន្តរជាតិ ដែលខិតខំធ្វើទំនើបនីយកម្ម ក្នុងនាមជាការអភិវឌ្ឍសេដ្ឋកិច្ចសង្គម ។[៥៥] ដោយសារតែសារជាតិនៃគោល

[៥៤] សូមមើលទូទៅ Clement Tisdell, *Global Warming and the Future of Pacific Island Countries*, 35:12 INT'L J. SOC. ECONOMICS, 889 (ខែតុលា ឆ្នាំ ២០០៨).

[៥៥] MARK FINDLAY និពន្ធសៀវភៅមានចំណងជើងថា THE GLOBALISATION OF CRIME: UNDERSTANDING THE TRANSITIONAL RELATIONSHIPS OF CRIME IN A GLOBAL CONTEXT (បោះពុម្ពដោយ Cambridge University Press ឆ្នាំ១៩៩៩) ជំពូក ២ ។

នយោបាយអភិវឌ្ឍន៍នេះ វប្បធម៌ពីងផ្អែក បានមកជំនួសការគ្រប់គ្រង និងកាតព្វកិច្ចអាណានិគម ដែលធ្វើឲ្យរីកលូតលាស់នូវឥទ្ធិពលបំផ្លិចបំផ្លាញវប្បធម៌នៃការចាត់ចែងជំនួយ ការកេងប្រវ័ញ្ចពាណិជ្ជកម្ម និងការដោះដូរទំនិញ ។ ជាជាងការអភិវឌ្ឍសេដ្ឋកិច្ចសង្គមដែលជំរុញឲ្យមានការរួមបញ្ចូលទៅក្នុងវិសាលភាពវិជ្ជមាននៃសកលភាវូបនីយកម្មទូទាំងតំបន់ ប្រវត្តិសាស្រ្តអាណានិគមនៃទ្វេភាគីនិយមរីករាលដាលពាសពេញទំនាក់ទំនងការទូត និងពាណិជ្ជកម្មនៅក្នុង និងខាងក្រៅតំបន់អាស៊ី និងប៉ាស៊ីហ្វិក ។ នៅពេលដែលរដ្ឋទាំងនោះទន់ខ្សោយ បែកខ្ញែកគ្នា ការពឹងផ្អែកលើជាលក្ខណៈទ្វេភាគី និងកាតព្វកិច្ចអាចជាឧបសគ្គដល់យុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិ ដែលតាមរយៈនេះ រដ្ឋដែលមានអំណាចនៅពិភពលោកខាងជើង អាចតវ៉ាដើម្បីតម្រូវឲ្យមានការគាំទ្រស្ម័យភាព និងផលប្រយោជន៍ជាតិរបស់ខ្លួន ជាថ្នូរនឹងការគាំទ្រផ្នែកសេដ្ឋកិច្ច និងយោធាមកវិញ ។

អ្វីដែលធ្វើឲ្យអវត្តមាននៃការឈានទៅដល់កម្រិតសាកល ក្លាយជាបញ្ហានៅតំបន់អាស៊ីប៉ាស៊ីហ្វិកនោះ គឺអន្តភាពនយោបាយ ឬរដ្ឋធំៗមួយចំនួនធំ ដែលមានបញ្ហាប្រឈមនៅក្នុងស្រុកច្រើន (ដូចជាស្ថេរភាពស្បៀង ភាពស្អិតរមួតខាងវប្បធម៌ ការបង្ខូចបរិស្ថាន ជាដើម) រួមជាមួយនឹងអវត្តមាននៃសាមគ្គីភាពផ្នែកនយោបាយ និងសេដ្ឋកិច្ចក្នុងតំបន់យ៉ាងច្បាស់ក្រឡែត ដែលប្រហែលជាអាចធ្វើអំណះអំណាងឲ្យមានការរួមបញ្ចូលទៅក្នុងកម្រិតសាកល ឬ យ៉ាងហោចណាស់ ទប់ទល់នឹងហានិភ័យនៃការកេងប្រវ័ញ្ចរបស់លោកខាងជើងទាំងអស់គ្នា ។ ដោយឡែក នៅពេលនិយាយដល់ការបំផ្លិចបំផ្លាញខាងពាណិជ្ជកម្មលើធនធានធម្មជាតិ តំបន់នេះទទួលរងឥទ្ធិពលអាក្រក់ពីសាកលភាវូបនីយកម្ម ដែលព្រមពេលជាមួយគ្នានោះត្រូវបានដកចេញមិនឲ្យទទួលផលប្រយោជន៍ជាដុំកំភួនទៅវិញ ។
នៅក្នុងស្ថានភាពបែបនេះ ចំណូលចិត្តអន្តរជាតិនិយម ឬជំនឿទុកចិត្តលើវិស័យយុត្តិធម៌អន្តរជាតិមានតិចតួចណាស់ ។

ភាពស្មុគស្មាញនេះ មានសភាពកាន់តែខ្លាំងឡើង ដោយសារតែការយល់ដឹងមិនគ្រប់គ្រាន់ពីរបៀបដែលតុលាការព្រហ្មទណ្ឌអន្តរជាតិដំណើរការ ។ ជាងនេះទៅទៀត គឺកង្វះការយល់ដឹងអំពីគោលការណ៍បំពេញបន្ថែម (the principle of complementary) ។ ទោះបីជារដ្ឋមួយផ្តល់សច្ចាប័នលើលក្ខន្តិកៈទីក្រុងរ៉ូមក៏ដោយ តុលាការជាតិរបស់រដ្ឋនោះនៅតែមានយុត្តាធិការក្នុងការស៊ើបអង្កេត និងជំនុំជម្រះឧក្រិដ្ឋកម្មដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិដដែល ។ លើកលែងតែក្នុងករណីដែលយន្តការយុត្តិធម៌ក្នុងស្រុកមិនមានលទ្ធភាព ឬខ្វះឆន្ទៈក្នុងការបំពេញមុខងារស៊ើបអង្កេត និង

កាត់ទោស ទើបតុលាការព្រហ្មទណ្ឌអន្តរជាតិឈានដើរចូលចាប់ផ្តើមការស៊ើបអង្កេត និងជំនុំជម្រះ ។[៥៦] ដូច្នេះ តុលាការព្រហ្មទណ្ឌអន្តរជាតិនៅតែត្រូវទាក់ទងរដ្ឋនោះ និងត្រូវធ្វើការសម្រេចចិត្តទៅតាមសំណុំរឿងនីមួយៗ បើទោះបីជាមានការផ្តល់សច្ចាប័នក៏ដោយ ។ សមាជិកភាពរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ នឹងមិនដកហូតស្វ័យភាពនៃប្រព័ន្ធតុលាការជាតិទេ ពោលគឺប្រជាពលរដ្ឋនៃរដ្ឋនោះ មិនអាចនាំយកសំណុំរឿងប្តឹងទៅតុលាការព្រហ្មទណ្ឌអន្តរជាតិដោយផ្ទាល់ឡើយ ។[៥៧]

ដូច្នេះ អ្នកគាំទ្រទាំងឡាយ គួរតែព្យាយាមបញ្ជាក់ឲ្យបានច្បាស់នូវព្រំដែនកំណត់ជាក់ស្តែងនៃយុត្តាធិការរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ឬ ត្រូវកំណត់ឲ្យកាន់តែច្បាស់ជាងមុននូវទេសៈកាលៈចាំបាច់ទាំងឡាយសម្រាប់ការអនុវត្តយុត្តាធិការរបស់តុលាការ ។ ការបញ្ជាក់ឲ្យបានច្បាស់លាស់បែបនេះនឹងមានឥទ្ធិពលបន្ថយការយល់ខុសរបស់រដ្ឋខ្លះដែលមានការសង្ស័យថា សមាជិកភាពនៅក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិអាចនឹងបន្ថែមកាតព្វកិច្ចខាងក្រៅបន្ថែមទៀត ដែលតាមរយៈនេះ ខ្លួនពុំមានឥទ្ធិពលផ្នែករដ្ឋបាល និងនយោបាយទាល់តែសោះ ។

## ៦.៣. សំណល់ក្រោយអាណានិគម

វាជារឿងសមរម្យដែលនិយាយថា ដូចគ្នានឹងតំបន់ក្រោយអាណានិគមដែរ នៅក្នុងរដ្ឋទទួលបានឯករាជ្យថ្មីៗនៅតំបន់អាស៊ី និងប៉ាស៊ីហ្វិក មានការបង្ហាញឲ្យឃើញនូវភាពភ័យខ្លាចដែលនៅសេសសល់អំពី«បស្ចឹមភាវូបនីកម្ម» ។ ភាពតានតឹង ស្តែងឲ្យឃើញយ៉ាងច្បាស់ក្រឡែត រវាងភាពមិនចេះទ្រុឌទ្រោមនៃវប្បធម៌រឹងមាំរបស់អ្នកស្រុក និងតម្រូវការនៃលុយខុសច្បាប់ ។ ការសាយភាយនូវភាពជ្រុលនិយមខាងផ្នែកសាសនា ហាក់បីដូចជា មានទំនោរនិយាយអាក្រក់ពីវប្បធម៌លោកខាងលិចថែមទៀត ។

ដើម្បីរ៉ាយរ៉ាប់ឲ្យបានច្បាស់លាស់ពីការអាក់អន់ចិត្តក្រោយអាណានិគម ការចងចាំថ្មីៗអំពីសកម្មភាពអាណានិគមហួសហេតុដែលស្តែងឲ្យឃើញតាមរយៈយន្តការយុត្តិធម៌ព្រហ្មទណ្ឌ មានពាសពេញប្រវត្តិឯករាជ្យនៃស្ថាប័នយុត្តិធម៌ព្រហ្មទណ្ឌថ្នាក់តំបន់ដែលគាំទ្រដោយរដ្ឋ ហើយដំណើរការ

---

[៥៦] សូមមើលលក្ខន្តិកៈទីក្រុងរ៉ូម, កំណត់ចំណាំ លេខ ២ ខាងដើម, មាត្រា ១៧ ។

[៥៧] Usman Hamid, *Why Indonesia, Asia Must Ratify the Rome Statute*, JAKARTA POST, Nov. 15, 2011, អាចរកបាននៅលើគេហទំព័រ http://www.thejakartapost.com/news/2011/11/15/why-indonesia-asia-must-ratify-rome-statute.html ។

ក្លាយទៅជាតំណាង និងបានធ្វើឲ្យកើតមានជាប្រចាំ តាមរយៈរដ្ឋបាលក្រោយអាណានិគមរបស់ពួកអ្នកអេលីត ពោលគឺការគ្រប់គ្រងយ៉ាងរើសអើងដោយអ្នកមានអំណាចលើពលរដ្ឋ ជាជាងជាប្រព័ន្ធយុត្តិធម៌សកល ។

នៅតំបន់អាស៊ី និងប៉ាស៊ីហ្វិក ចលនាបម្លាស់ទីកាលពីបុរាណ មានន័យថា វប្បធម៌ដើមរបស់អ្នកស្រុកប្រឈមមុខនឹងអាណានិគមជាប្រចាំ ។ បន្ថែមពីលើកំណាប់ទ្រព្យពាណិជ្ជកម្មដែលទាក់ទាញលោកខាងលិចទៅលោកខាងកើត ហើយវាមិនពិបាកយល់ពីមូលហេតុ នៅពេលចំណាងនៃការគ្រប់គ្រងអាណានិគមត្រូវបានបញ្ចេញ មិនមានចំណង់ចំណូលចិត្តដើម្បីសម្រុះសម្រួលស៊័យភាពដែលបានមកយ៉ាងលំបាក ទៅដោះដូរជាថ្នូរនឹងយុត្តិធម៌បែបលោកខាងលិច ដែលអាចតំណាងឲ្យឥទ្ធិពលចក្រពត្តិមួយជាន់ទៀតឡើយ ។

ដោយឡែក ដោយសារតែវប្បធម៌អាស៊ីមានមន្ទិលសង្ស័យ បានធ្វើឲ្យមានការយល់ខុសអំពីអន្តរជាតូបនីយកម្ម ឬភាពមិនស៊ីសង្វាក់គ្នា ដែលត្រូវបានបកស្រាយថា ជាការធ្វើឲ្យដូចលោកខាងលិចនោះ សេដ្ឋកិច្ចអាស៊ីដែលកំពុងអភិវឌ្ឍន៍ ឬស្ថិតក្នុងអន្តរកាល បានយករដ្ឋបាលលោកខាងលិច និងការរៀបចំខាងពាណិជ្ជកម្ម មកកែប្រែឲ្យស្របទៅនឹងអាទិភាពរបស់ខ្លួន ។ បើទោះបីជាមានបែងអំពីកាតព្វកិច្ចធម្មនុញ្ញក៏ដោយ នៅក្នុងក្របខ័ណ្ឌនយោបាយ និងសង្គមនៅតំបន់អាស៊ីជាច្រើន សិទ្ធិជាលក្ខណៈបុគ្គលដែលនិយាយថា ចន្លុលបង្ហាញយុត្តិធម៌ព្រហ្មទណ្ឌតាមគោលការណ៍លោកខាងលិច ប្រហែលជាមិនត្រូវបានឲ្យតម្លៃខ្ពស់ជាងភាពស្អិតរមួតខាងផ្នែកសហគមន៍ឡើយ ។ កុលសម្ព័ន្ធនៅតាមកោះក្នុងតំបន់ប៉ាស៊ីហ្វិកមានអាទិភាពស្រដៀងគ្នានេះដែរ ។

ជាធម្មតា រដ្ឋជាកោះនៅតំបន់ប៉ាស៊ីហ្វិករក្សាទុកលក្ខណៈនៃការគ្រប់គ្រងតាមបែបសភាប្រទេសអង់គ្លេស ។ ប៉ុន្តែ ដោយសារតែក្របខណ្ឌការងារទាំងនេះមិនសាកសមនឹងរចនាសម្ព័ន្ធសង្គមដែលមានកាតព្វកិច្ចស្មុគស្មាញច្រើន និងកាតព្វកិច្ចចំណងប្រពៃណីចំពោះសហគមន៍ ត្រូវបានប្រើខុសតាមរយៈអំពើពុករលួយ និងការកេងប្រវ័ញ្ច ។[៥៨] ពួកអេលីតខាងនយោបាយដែលប្រព្រឹត្តអំពើពុករលួយមានផលប្រយោជន៍ បានធ្វើខ្លួនឲ្យនៅឆ្ងាយពីស្ថាប័នអភិបាលកិច្ច និងការទទួលខុសត្រូវ ដូចជា ស្ថាប័នយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិ ជាដើម ។[៥៩]

---

[៥៨] សូមមើលទូទៅ Mark Findlay, *Misunderstanding Corruption and Community: Comparative Cultural Politics of Corruption Regulation in the Pacific*, 2:1 ASIAN J. CRIMINOLOGY 47 (មិថុនា ២០០៧) ។

[៥៩] សូមមើលទូទៅ MARK FINDLAY, GOVERNING THROUGH GLOBALISED CRIME (Willian បោះពុម្ពផ្សាយនៅឆ្នាំ ២០០៨) ។

ដោយសារតែស្ថាប័នផ្សេងៗនៃយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិ និងយន្តការអភិបាលកិច្ចអន្តរជាតិដែលឧបត្ថម្ភស្ថាប័នទាំងនោះ ត្រូវបានរដ្ឋនៅតំបន់អាស៊ី-ប៉ាស៊ីហ្វិកតូចៗចាត់ទុកថាតំណាងឲ្យអនុត្តរភាពផ្នែកសេដ្ឋកិច្ច និងនយោបាយសកលលោកនោះ ទើបប្រទេសទាំងនោះចង់គេចវេះចេញ ។ ចំពោះរដ្ឋក្រោយអាណានិគមនៅអាហ្វ្រិក និងអាមេរិចខាងត្បូងដែលអាចមានខដាក់លក្ខខណ្ឌដូចគ្នា, រដ្ឋទាំងឡាយដែលហែកហួរដោយសារជម្លោះយោធាក្នុងស្រុក និងការតស៊ូនយោបាយ ឬប្រទេសដែលញាំញីដោយចលនាអបគមន៍វិញ អាចស្ម័គ្រចិត្តសូម្បីតែទំនាក់ទំនងជាមួយការគ្រប់គ្រងអនុត្តរភាព ដោយសង្ឃឹមថាទទួលបានការពេញចិត្តខាងផ្នែកនយោបាយ ឬ ដំណោះស្រាយជម្លោះតាមរយៈការធ្វើច្បាប់ព្រហ្មទណ្ឌសម្រាប់ដាក់ទោសសត្រូវរបស់ពួកគេ ។

មានតែតាមរយៈការធ្វើការទំនាក់ទំនង និងការពិគ្រោះយោបល់ជាមួយនឹងរដ្ឋសមាជិកប៉ុណ្ណោះ ទើបការអភិវឌ្ឍយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិកើតមានឡើងតាមរយៈស្ថាប័នផ្សេងៗរបស់រដ្ឋ និងដោយសារតែតុលាការព្រហ្មទណ្ឌអន្តរជាតិ នៅត្រឹមកម្រិតណាមួយនោះ ស្ថិតនៅក្រោមផលប្រយោជន៍នៃរដ្ឋដែលមានអំណាច ដូចជាសមាជិកអចិន្ត្រៃយ៍នៃអង្គការសហប្រជាជាតិនោះ វាចាំបាច់ត្រូវបើកចំហរទទួលយកឥទ្ធិពលពីរដ្ឋតូចៗ ឬរដ្ឋដែលមិនសូវមានអនុត្តរភាព និងទំនៀមទម្លាប់របស់គេដែលធ្លាប់ធ្វើកន្លងមក ។[៦០] តុលាការព្រហ្មទណ្ឌអន្តរជាតិអាចឆក់យកអន្តរកាលរបស់អង្គការសហប្រជាជាតិដែលកំពុងតែផ្តោតទៅលើគំរូយុត្តិធម៌មួយដែលទូលំទូលាយជាងមុនជាសញ្ញាណដើម្បីធ្វើឲ្យយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិចូលក្នុងដំណើរផ្តល់យុត្តិធម៌មួយដែលមានលក្ខណៈចម្រុះវប្បធម៌បំផុត (ជាជាងមានលក្ខណៈនយោបាយបោះៗ) ។ មធ្យោបាយបញ្ចូលចម្រុះវប្បធម៌បំផុតនេះ បំពេញតម្រូវការសម្រាប់ការអភិវឌ្ឍខ្លឹមសារច្បាប់ព្រហ្មទណ្ឌអន្តរជាតិ និងនីតិវិធីដែលទទួលស្គាល់ការទទួលខុសត្រូវផ្លូវច្បាប់រួម អង្គការឧក្រិដ្ឋ និងការទទួលខុសត្រូវរបស់សហគមន៍ជនល្មើស ចំពោះសហគមន៍ជនរងគ្រោះ ។[៦១]

## ៦.៤. អត្តសញ្ញាណវិធានបទដ្ឋាន

ពាក្យថា "តម្លៃអាស៊ី" និង "របៀបប៉ាស៊ីហ្វិក" ត្រូវបានប្រើប្រាស់ជាទូទៅក្នុងការពន្យល់ពីការកំណត់ស្វ័យភាពនយោបាយ និងការចូលរួមជាលក្ខណៈតំបន់នៅទូទាំងតំបន់ ។

ឧទាហរណ៍ ប្រសិនបើនរណាម្នាក់សិក្សាពីការអភិវឌ្ឍប្រពៃណីយុត្តិធម៌ព្រហ្មទណ្ឌក្នុងការគាត់នៅតំបន់អាស៊ី និងប៉ាស៊ីហ្វិក យ៉ាងហោចណាស់ គេនឹងពន្យល់ដោយផ្អែកដោយទស្សនៈខុសៗគ្នាអំពីយុត្តិធម៌

---

[៦០] សូមមើលទូទៅ Findlay, កំណត់ចំណាំខាងដើម ៩ ។

[៦១] សូមមើលទូទៅ ស្តន ។

និងអំពីការទទួលខុសត្រូវរបស់ពលរដ្ឋ ជាជាងពន្យល់ពីអ្វីដែលមានលើសលប់នៅក្នុងពិភពលោកខាងជើង ឬយុត្តិធម៌បែបលោកខាងលិច ដែលជាម៉ូដែលប្រើប្រាស់លើសលប់នៅក្នុងយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិ ។ ជាថ្មីម្តងទៀត ការប្រើប្រាស់ភាពខុសប្លែកគ្នានៃវិធានបទដ្ឋានជាការពន្យល់អំពីភាពស្ទាក់ស្ទើរក្នុងការចូលរួមជាមួយនឹងយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិអាចត្រូវលើកហេតុផលជំទាស់ផ្ទុយវិញ ដោយឧទាហរណ៍ជាច្រើននៅអាហ្វ្រិក និងអាមេរិកខាងត្បូង ដែលរដ្ឋទាំងនោះចង់ថែរក្សាអធិបតេយ្យភាពរបស់ខ្លួនដូចគ្នាដែរ ប៉ុន្តែបានចុះហត្ថលេខាលើលក្ខន្តិកៈទីក្រុងរ៉ូម ។ តើមានអ្វីផ្សេងទៀតដែរឬទេ ដែលជះឥទ្ធិពលលើលក្ខណៈពិសេសនៃវិធានបទដ្ឋាននៅតំបន់អាស៊ី និងប៉ាស៊ីហ្វិក?

ការពិនិត្យកាន់តែជ្រៅទៅក្នុងអត្តសញ្ញាណវិធានបទដ្ឋាន នៅកម្រិតរដ្ឋ បានបង្ហាញឲ្យឃើញពីគ្រោះថ្នាក់ក្នុងការនិយាយជាសរុបនៃវិធានបទដ្ឋាននៅក្នុងតំបន់ដែលមានការអភិវឌ្ឍ និងវប្បធម៌ខុសៗគ្នាបែបនេះ ។ ដោយទទួលស្គាល់បែបនេះ និងដោយក្រឡេកមើលរដ្ឋធម្មនុញ្ញរបស់រដ្ឋនៅក្នុងតំបន់ដែលស្ថិតនៅក្រៅតុលាការព្រហ្មទណ្ឌអន្តរជាតិនៅឡើយ ស្ថិរភាពនយោបាយ និងវប្បធម៌ក្រោយអាណានិគមគឺមិនខុសគ្នាទេ ។ ការបង្កប់នូវអត្តសញ្ញាណនយោបាយឯករាជ្យមួយទៅក្នុងគ្រឹះវប្បធម៌ ដែលត្រូវបានបង្កើតយូរមកហើយនោះ សូម្បីតែនៅក្នុងរដ្ឋក្រោយអាណានិគមដែលងាយបែកបាក់នៅតំបន់អាស៊ី និងប៉ាស៊ីហ្វិក ក៏ត្រូវបានយល់ស្របយ៉ាងទៀងទាត់តាមរយៈក្របខ័ណ្ឌនយោបាយមជ្ឈការ ឬ ដែលមានគេបញ្ជាពីខាងក្រោយខ្លាំង ដែលអបអរសាទរអធិបតេយ្យភាព ។ សម្ព័ន្ធភាពសេដ្ឋកិច្ច និងនយោបាយក្នុងតំបន់ខ្សោយនៅអាស៊ី និងប៉ាស៊ីហ្វិក គឺជាភស្តុតាងបន្ថែមទៀតនៃស្វ័យភាពដែលមិនងាយទ្រុឌទ្រោមរបស់រដ្ឋ ។

ដើម្បីឆ្លើយនឹងកង្វល់បែបនេះ តុលាការព្រហ្មទណ្ឌអន្តរជាតិ អាចធ្វើបានច្រើនជាងនេះដើម្បីបង្ហាញពីរបៀបដែលថា ការឲ្យសច្ចាប័នលើលក្ខន្តិកៈទីក្រុងរ៉ូម បានគូសបញ្ជាក់ ប៉ុន្តែ មិនកាត់បន្ថយនូវស្វ័យភាពរបស់រដ្ឋទេ ដោយបានយកចិត្តទុកដាក់ទៅលើទិដ្ឋភាពពិសេសខុសៗគ្នានៃយុត្តិធម៌មួយបែបដែលមិនមានវត្តមានទេ ទើបតែពេលឥឡូវនេះប៉ុណ្ណោះ ។ ការចូលរួមជាមួយតុលាការព្រហ្មទណ្ឌអន្តរជាតិ គឺជាឱកាសសម្រាប់រដ្ឋនៅតំបន់អាស៊ី និងរដ្ឋជាកោះនៅប៉ាស៊ីហ្វិក ដើម្បីដាក់បញ្ចូលនូវអត្តសញ្ញាណវិធានបទដ្ឋានរបស់ខ្លួន តាមរយៈការជះឥទ្ធិពលលើការការបង្កើតយុត្តិសាស្ត្រព្រហ្មទណ្ឌសកល ។

នៅក្នុងករណីប្រទេសចិន ការយល់ឃើញនៅក្នុងទស្សនៈខុងជឺ និងកុម្មុយនីស្ត ដែលចាត់ទុកសណ្តាប់ធ្នាប់សង្គមសំខាន់ជាងបុគ្គល ដូចដែលមានទទួលស្គាល់នៅក្នុងប្រព័ន្ធច្បាប់ព្រហ្មទណ្ឌរបស់គេ (ចក្រពត្តិ និងទំនើប) ផ្តល់នូវមូលដ្ឋានអំណោយផលសម្រាប់ការលូតលាស់នៃការអនុវត្តដំណោះស្រាយ

សម្រាប់សមាជិកសហគមន៍ ដូចជា ការចូលរួមរបស់ជនរងគ្រោះនៅក្នុងដំណើរការផ្សះផ្សា និងជំនុំជម្រះក្តី និងសិទ្ធិរបស់ជនរងគ្រោះក្នុងការទទួលបានសំណងការខូចខាតជាដើម ។[៦៧] ដូច្នេះ ការចូលរបស់ប្រទេសចិនទៅក្នុងការជជែកពិភាក្សាអំពីតុលាការព្រហ្មទណ្ឌអន្តរជាតិ ដែលពាំនាំមកជាមួយនូវការពិចារណាអំពីសិទ្ធិជារួម មានសក្តានុភាពធំសម្បើមសម្រាប់ទប់ស្កាត់ឧក្រិដ្ឋកម្មដែលមានលក្ខណៈជារួម និងសម្រាប់សណ្តាប់ធ្នាប់សង្គមដែលធ្លាក់ចុះធ្ងន់ធ្ងរ ដើម្បីប្រកាន់តួនាទីមួយប្រសើរជាងមុននៅក្នុងយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិ ។

## ៦.៥. ធម្មនុញ្ញភាព

ការពន្យល់មួយទៀតពីការស្ទាក់ស្ទើរចូលរួមជាមួយតុលាការយុត្តិធម៌អន្តរជាតិ នៅទូទាំងតំបន់គឺទាក់ទងនឹងធម្មនុញ្ញភាព ។ រដ្ឋជាកោះនៅតំបន់អាស៊ី និងប៉ាស៊ីហ្វិក បានបង្ហាញឲ្យឃើញនូវប្រវត្តិសិទ្ធិមនុស្សដ៏អាក្រក់ម្តងហើយម្តងទៀត បើគិតទៅតាមស្តង់ដាររបស់អង្គការសហប្រជាជាតិ បើទោះបីជាមានការរីកសាយភាយនៅក្នុងរដ្ឋធម្មនុញ្ញដែលមានលក្ខណៈល្អិតល្អន់ ដោយមានបញ្ចូលនូវបញ្ហាសិទ្ធិមនុស្ស និងក្រមនៃភាពជាអ្នកដឹកនាំដែលហាក់ដូចជា «ផ្តោតលើសិទ្ធិ» ក៏ដោយ ។ ភាពផ្ទុយគ្នានេះ អាចត្រូវបានពន្យល់តាមរយៈការអនុវត្តដែលមានបង្កប់នូវបញ្ហានៃរបបសភានិយមតាមប្រទេសអង់គ្លេស និងតាមរយៈដំណាក់កាលដែលពុករលួយ និងដែលមិនសូវអភិវឌ្ឍ នៃលទ្ធិប្រជាធិបតេយ្យតាមបែបតំណាង ។ នៅក្នុងរដ្ឋ ដូចជាប្រទេសចិន ការពន្យល់ផ្សេងមួយទៀត គឺភាពមិនស៊ីសង្វាក់គ្នារវាងការពិភាក្សាអំពីធម្មនុញ្ញភាពនិយម និងការនៅមានជាបន្តនូវប្រពៃណីរដ្ឋបាលដែលពឹងផ្អែកលើឆន្ទានុសិទ្ធិបុគ្គលដែលមានលក្ខណៈទូលំទូលាយ និងមិនទទួលខុសត្រូវ ។

ការសង្កត់ធ្ងន់លើគោលការណ៍សិទ្ធិមនុស្សធម៌ ដែលជាគ្រឹះរបស់ស្ថាប័នដូវការនៃយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិ មិនស៊ីសង្វាក់គ្នាជាមួយក្របខណ្ឌនយោបាយ ដែលជាក់ស្តែង មិនគោរពការការពារសិទ្ធិហើយផ្ទុយទៅវិញ ពឹងផ្អែកលើការអនុវត្តក្រៅផ្លូវការខាងផ្នែកនយោបាយ និងវប្បធម៌ (ដូចជាភក្តីភាពចំពោះក្រុម) ដែលបានធ្វើឲ្យមានការប៉ះពាល់ដល់ដំណើរការទទួលខុសត្រូវចំពោះការរំលោភសិទ្ធិ ។ ជាថ្មីម្តងទៀត អ្វីដែលអាចញែកភាពស្ទាក់ស្ទើរនៅក្នុងតំបន់ដែលផ្អែកលើភាពផ្ទុយគ្នាខាងលើចំពោះការអនុវត្តសិទ្ធិមនុស្សចេញពីតំបន់ផ្សេងៗ ដែលរដ្ឋទាំងនោះបានចុះហត្ថលេខាលើលក្ខន្តិកៈទីក្រុងរ៉ូម ខណៈពេលដែលមិនឲ្យតម្លៃលើការទទួលខុសត្រូវខាងនយោបាយ និងសិទ្ធិ គឺអវត្តមានដែល

[៦៧] ដូចខាងលើ ។

គួរឲ្យកត់សម្គាល់នៃរបនាសម្ព័ន្ធសិទ្ធិនៅក្នុងតំបន់អាស៊ី រួមផ្សំនឹងប្រវត្តិនៃរបបនយោបាយថ្មីៗដែលអនុវត្ត (មួយចំនួនកំពុងបន្តអនុវត្ត) ការគាបសង្កត់សិទ្ធិជាប្រព័ន្ធ ។

មានការរំពឹងទុកថា អន្តរាគមន៍របស់តុលាការព្រហ្មទណ្ឌអន្តរជាតិនឹងមានភាពទំនង និងទាក់ទាញកាន់តែខ្លាំងឡើងៗសម្រាប់រដ្ឋ នៅពេលសមត្ថភាពយុត្តិធម៌ព្រហ្មទណ្ឌក្នុងស្រុករបស់ខ្លួន និងជាពិសេសនៅពេលដែលទីតាំងនៃដំណើរការវិនិច្ឆ័យទោសនៅក្នុងនិត្យានុកូលភាពធម្មនុញ្ញ ងាយបាក់បែក ងាយទទួលរងឥទ្ធិពល ឬងាយប៉ះពាល់ និងមិនឯករាជ្យ ។ គួរជាទីចាប់អារម្មណ៍ បើទោះបីជាការអភិវឌ្ឍផ្នែកសេដ្ឋកិច្ច និងសមត្ថភាពនយោបាយ មានកម្រិតខុសៗក៏ដោយ រដ្ឋទាំងឡាយនៅតំបន់អាស៊ីនិងប៉ាស៊ីហ្វិក (ប្រហែលជាមកពីផលវិបាកនៃគោលនយោបាយគ្រប់គ្រងបែបអាណានិគម) ជារឿយៗ តែងតែសម្តែងឲ្យឃើញនូវប្រពៃណី និងស្ថាប័នយុត្តិធម៌ព្រហ្មទណ្ឌដែលមិនងាយទ្រុឌទ្រោម មានលក្ខណៈមជ្ឈការ និងមានធនធានគួរសម ។ វាប្រហែលជាអាចផ្តល់ការលួងចិត្តខ្លះសម្រាប់ប្រទេសមួយដែលស្ទាក់ស្ទើរក្នុងការទទួលយកយុត្តាធិការអន្តរជាតិ ដែលដំណើរការយុត្តិធម៌ជាផ្លូវការរបស់រដ្ឋ មានសមត្ថភាពចាត់ចែងកិច្ចការផ្ទាល់ខ្លួន ទាក់ទិននឹងឧក្រិដ្ឋកម្មដែលស្ថិតនៅក្រោមយុត្តាធិការរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិបាន ។

## ៦.៦.ឆន្ទានុសិទ្ធិប្រតិបត្តិ

ដោយស្របនឹងការអង្កេតចុងក្រោយខាងលើ រដ្ឋជាច្រើននៅក្នុងតំបន់អាស៊ី និងប៉ាស៊ីហ្វិក ទទួលរងការប៉ះពាល់ដោយស្ថិតនៅក្រោមអំណាចផ្តាច់ការថ្មីៗ ឬការគ្រប់គ្រងដោយប្រើកម្លាំងទ័ព និងការធ្វើរដ្ឋប្រហារកន្លងមក ។ របបគ្រប់គ្រងតាមបែបមជ្ឈការនៅប្រទេសចិន, ឥណ្ឌា, ប៉ាគីស្ថាន, និងឥណ្ឌូនេស៊ី មានន័យថា ភាគច្រើននៃប្រជាជននៅក្នុងពិភពលោកទាំងមូលត្រូវតែគ្រប់គ្រងក្រោមកណ្តាប់ដៃដ៏តឹងរឹងរបស់រដ្ឋាភិបាលមជ្ឈការ ។

នៅក្នុងរបបគ្រប់គ្រងបែបនោះ វិស័យសន្តិសុខដែលពោរពេញដោយអំណាចនៅក្នុងផ្នែកយោធា និងប៉ូលីស មានលក្ខណៈរីកសាយភាយ ។ អភិបាលកិច្ចតាមរយៈការគម្រាមកំហែងពីផលវិបាកនៃការប្រឆាំង ឬជំទាស់ សម្រាប់ប្រជាពលរដ្ឋ មានន័យថា មិនសូវមានការរិះគន់ទេនៅក្នុងសង្គមស៊ីវិល ។ សេរីភាពក្នុងការបញ្ចេញមតិ ប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ និងអង្គការនយោបាយផ្សេងៗ ត្រូវបានរឹតត្បិត ។ សហគមន៍ចាំតែគោរពតាម ។ នៅក្នុងបរិស្ថានដែលមានអភិបាលកិច្ចបែបនេះ ឆន្ទានុសិទ្ធរដ្ឋបាលគឺមានលក្ខណៈមជ្ឈការ រីករាលដាល និងមិនទទួលខុសត្រូវអ្វីទាំងអស់ចំពោះមុខប្រជាជន ប៉ុន្តែ ទទួល

ខុសត្រូវចំពោះមុខអ្នកមានអំណាចប៉ុណ្ណោះ ។ ដូច្នេះ ការអនុវត្តនិទ្ទណ្ឌភាពត្រូវបានអត់ឱនឲ្យដោយសារតែអ្នកដឹកនាំនៃរដ្ឋទាំងនោះ ជារឿយៗ គឺជាជនដៃដល់នៃឧក្រិដ្ឋកម្មធ្ងន់ធ្ងរ តាមរយៈការប្រព្រឹត្ត និងការមិនអើពើ ។ វាគ្មានអ្វីដែលគួរឲ្យភ្ញាក់ផ្អើលនោះទេដែលថា ការអញ្ជើញឲ្យចូលរួមក្នុងដំណើរការយុត្តិធម៌ដែលមានសក្តានុពលតម្រូវឲ្យដាក់ការទទួលខុសត្រូវជាអន្តរជាតិ ខ្ពស់ជាងផលប្រយោជន៍របស់រដ្ឋ មិនទំនងជាទទួលបានចំណាប់អារម្មណ៍ពីរដ្ឋាភិបាល ដែលតែងតែបដិសេធនូវកាតព្វកិច្ចទទួលខុសត្រូវក្នុងស្រុករបស់ខ្លួននោះ ។

## ៦.៧. សង្គមស៊ីវិល

នៅទូទាំងតំបន់អាស៊ី-ប៉ាស៊ីហ្វិក ភាពមិនចាស់ទុំនៃសង្គមស៊ីវិលក្នុងនាមជាកងកម្លាំងនយោបាយមានន័យថា ការគាំទ្រយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិនៅតាមមូលដ្ឋាន គឺ លំបាកនឹងប្រមូលបានណាស់ ។[៦៣] ជាកុលសម្ព័ន្ធនិយម ប្រព័ន្ធវណ្ណៈ និងឋានានុក្រមវប្បធម៌ ហាក់បីដូចជាបានបែងចែកសង្គមស៊ីវិលជាថ្នាក់ៗ និង បានរារាំងចលនាជនរងគ្រោះដែលអាចដាក់សម្ពាធឲ្យមានការចូលរួមជាមួយយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិ ។ នៅក្នុងបរិស្ថាននយោបាយបែបនេះ អង្គការក្រៅរដ្ឋាភិបាល ជារឿយៗត្រូវបានរឹតត្បិត ហើយការបែកបាក់នៃចលនានយោបាយប្រឆាំង បានធ្វើឲ្យការគាំទ្រយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិនៅក្នុងប្រទេស ជួបការលំបាក ។

លក្ខណៈពិសេសមួយរបស់សង្គមស៊ីវិលនៅក្នុងតំបន់ គឺការពេញចិត្តចំពោះអ្វីដែលខ្លួនធ្វើបាន ។ នេះមិនមែនជាផលវិបាកនៃភាពភ័យខ្លាចចំពោះការគាបសង្កត់នោះទេ ។ ជាក់ស្តែង នៅក្នុងករណីនៃប្រទេស សិង្ហបុរី ការគ្រប់គ្រងដែលមានលក្ខណៈផ្តាច់ការត្រូវបានដាក់ឲ្យអនុវត្ត និងថែរក្សា តាមរយៈការរីកចម្រើនផ្នែកសេដ្ឋកិច្ច និងសម្ភារ ។ សង្គមដែលស្ថិតក្នុងកាលៈទេសៈបែបនោះ គោរពតាមរដ្ឋាភិបាល ដោយយល់ថា ការមិនគោរពតាម មានផលប៉ះពាល់ដល់ផលប្រយោជន៍ខាងផ្នែកសេដ្ឋកិច្ច-សង្គម ។ លើសពីនេះទៀត ទោះបីជាគម្លាតទ្រព្យសម្បត្តិនៅសិង្ហបុរីជាបញ្ហាយ៉ាងច្បាស់មួយ នៅទូទាំងពិភពលោកក៏ដោយ ទ្រឹស្តីនៃរបបដែលឲ្យសិទ្ធិប្រជាជាជនជាធំ បានដាក់ការទទួលខុសត្រូវក្នុងការបង្កើតទ្រព្យសម្បត្តិទៅលើរូបវន្តបុគ្គល ដោយបានដកចេញពីរដ្ឋនូវភារកិច្ចទាំងឡាយដើម្បីរៀបចំតុល្យភាព និងដើម្បីក្លាយជាចំណុចផ្តោតរបស់ក្រុមអ្នកដែលមានការខ្វះខាតធនធាន ។

---

[63] Coalition for the International Criminal Court website, A Universal Court with Global Support, *at* http://www.iccnow.org/?mod=ratimp.

សំណាញ់កាតព្វកិច្ច និង ការគ្រប់គ្រងដ៏ស្មុគស្មាញ គឺជាលក្ខណៈមួយនៃសង្គមស៊ីវិលដែលអនុវត្តន៍តាមតែបញ្ញា ។ ជំរុញដោយគំរូនៃការអភិវឌ្ឍដោយប្រើលុយខុសច្បាប់ និងដោយការជួញដូរទំនិញ ទំនាក់ទំនងទាំងនេះអាចនឹងជំរុញឲ្យមានអំពើពុករលួយ ដែលអាចគ្រប់គ្រងលើសង្គមស៊ីវិលតាមរយៈការផ្តល់ និងទទួលផលប្រយោជន៍ ។[៦៤]

ភាពដូចគ្នាសម្រាប់ទាំងរដ្ឋមជ្ឈការនិយម និងនិយមមានគេបញ្ញាពីក្រោយខ្នង នៅក្នុងតំបន់គឺស្ថិតនៅត្រង់របៀប ដែលរដ្ឋទាំងនោះដកសង្គមស៊ីវិលចេញពីអភិបាលកិច្ចតាមចូលរួម ឬខកខានមិនបានធ្វើឲ្យមានការចូលរួមខ្លាំងលើសពីកាតព្វកិច្ចដែលរដ្ឋបានកំណត់ ។[៦៥] កាតព្វកិច្ចទាំងនេះត្រូវបានបង្កើតឡើងដើម្បីបំពេញបន្ថែមលើជំនឿវប្បធម៌សំខាន់ៗ ដែលចាំបាច់តម្រូវឲ្យមានការគោរពតាម និង ដែលដាក់ឲ្យអនុវត្តនូវការប្រកាន់ខ្ជាប់យ៉ាងអភិរក្សទៅតាមសណ្តាប់ធ្នាប់តឹងរឹង ក្នុងករណីចាំបាច់ ។

អ្នកតស៊ូមតិឲ្យមានការផ្តល់សច្ចាប័ន គួរតែធ្វើឡើងតាមរយៈសង្គមស៊ីវិល នៅក្នុងរដ្ឋរឹតត្បិតសេរីភាព ដើម្បីកេងប្រវ័ញ្ចលើសក្តានុពលខាងការទទួលខុសត្រូវ និងអភិបាលកិច្ចនៃយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិ ដែលបានដាក់បញ្ចូលទៅក្នុងស្ថាប័ន ដូចជាតុលាការព្រហ្មទណ្ឌអន្តរជាតិ ។[៦៦] ការជំរុញបែបនេះ ក៏អាចកើតចេញពីក្រុមបញ្ញវន្ត និងប្រព័ន្ធផ្សព្វផ្សាយ ដែលដើរតួនាទីក្នុងការជួយជ្រោមជ្រែងបង្កើតសក្តានុពលនៃការតស៊ូរបស់សង្គមស៊ីវិល ។

## ៧. សេចក្តីបញ្ចប់

ដើម្បីស្វែងយល់ដឹងពីអត្រាទាបនៃការចូលជាសមាជិក តុលាការព្រហ្មទណ្ឌអន្តរជាតិរបស់រដ្ឋជាសមាជិកនៅក្នុងតំបន់អាស៊ី-ប៉ាស៊ីហ្វិកទាំងមូល អត្ថបទនេះផ្តល់ការពន្យល់យ៉ាងច្រើន នៅក្នុងបរិបទសង្គម និងវប្បធម៌ ជាជាងការផ្តោតជាសំខាន់លើការសម្រេចចិត្តផ្នែកនយោបាយ ។ ការសន្និតគឺថាលក្ខខណ្ឌសង្គម ដែលជិតាស់នឹងការចូលរួមជាមួយតុលាការយុត្តិធម៌អន្តរជាតិ ដែលមានជាទូទៅនៅក្នុងរដ្ឋនៅទូទាំងតំបន់ អាចកំណត់បាន និងដោះស្រាយបាន ដោយកម្លាំងដែលជំរុញសមាជិកភាព

---

[៦៤] Elizabeth Kamaldin, *Singapore Needs to Change Its Filial-piety Mindset*, ASIAONE, Oct. 10, 2012 គេហទំព័រ http://www.asiaone.com/News/Latest%2BNews/Singapore/Story/A1Story20121010-376608.html.

[៦៥] សូមមើលទូទៅ Findlay, កំណត់ចំណាំខាងដើម ៥៩ ជំពូក ៩ ។

[៦៧] សូមមើលទូទៅ Findlay, កំណត់ចំណាំខាងដើម ៥៦ ជំពូក៩ ។

នៃតុលាការព្រហ្មទណ្ឌអន្តរជាតិ ។ ទោះបីជាយ៉ាងណាក៏ដោយ លក្ខខណ្ឌមួយចំនួន ដូចជាភាពជាប់ទាក់ទង និងសមត្ថភាព ចាំបាច់ត្រូវមានការកែប្រែនយោបាយ និងការអភិវឌ្ឍ ច្រើនជាងអ្វីដែលការលើកតម្កើងតម្លៃយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិអាចសម្រេចបាន ។ ការកែប្រែបែបនេះ គឺចាំបាច់នៅក្នុងរដ្ឋ និងពីស្ថាប័នដូវការរបស់យុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិផងដែរ ប្រសិនបើចង់ឲ្យការចូលរួមនៅក្នុងតំបន់ប្រព្រឹត្តទៅកាន់តែជោគជ័យ និងគួរឲ្យទាក់ទាញ ។

ការរីកចម្រើននៃការទទួលយករបស់រដ្ឋនូវផលប្រយោជន៍ពីអភិបាលកិច្ចសកល ដែលស្ថាប័នជាច្រើនដូចជា តុលាការព្រហ្មទណ្ឌអន្តរជាតិ អាច និងគួរផ្តល់ឲ្យ រង់ចាំមើលបញ្ហាប្រឈមពាក់ព័ន្ធសម្រាប់ច្បាប់អន្តរជាតិសាធារណៈ ។ ដោយសារតែការប្តេជ្ញាឲ្យមានការទទួលខុសត្រូវជាលក្ខណៈបុគ្គលចំពោះឧក្រិដ្ឋកម្មអន្តរជាតិ ចំណងសំខាន់(និងគោលបំណងសំខាន់) នៃច្បាប់អន្តរជាតិសាធារណៈ អាចត្រូវបានគេមើលឃើញហួសពីទំនាក់ទំនងរវាងរដ្ឋ និងរដ្ឋ ។ ការទទួលខុសត្រូវជាលក្ខណៈបុគ្គល តាមរយៈការជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិ ក៏ហួសពីសិទ្ធិជាបុគ្គលនៃច្បាប់មនុស្សធម៌អន្តរជាតិដែរ ។ ការវិវត្តនៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិ និងយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិ (ជារបៀបនៃអភិបាលកិច្ចជាសកល) បានធ្វើឲ្យការប្រើប្រាស់ច្បាប់អន្តរជាតិសាធារណៈកាន់តែច្រើនឡើងៗ ដើម្បីដោះស្រាយ«បញ្ហាធំៗ» ដែលជាកង្វល់ខុសៗគ្នាជាច្រើនរបស់រដ្ឋនៅតំបន់អាស៊ីប៉ាស៊ីហ្វិក ។ ច្បាប់អន្តរជាតិ អាចត្រូវបានពង្រឹងឲ្យកាន់តែមានលក្ខណៈល្អប្រសើរឡើងសម្រាប់រដ្ឋទាំងអស់នេះ គឺជាមធ្យោបាយក្នុងការធ្វើឲ្យមានការទទួលខុសត្រូវជាលក្ខណៈបុគ្គល និងជារួម ព្រមទាំងការស្វែងរកដំណោះស្រាយ នៅពេលដែលការទទួលខុសត្រូវត្រូវបានបដិសេធ ដោយសារតែអត្ថប្រយោជន៍នៅពីក្រោយការបកស្រាយច្បាប់អន្តរជាតិសាធារណៈចង្អៀតចង្អល់ និងការផ្សព្វផ្សាយប្រកបដោយសក្តានុពលរបស់វា ។ ឥឡូវនេះ សមាជិកភាពនៅក្នុងសម្ពន្ធ័យុត្តិធម៌អន្តរជាតិ នៅពេលនេះ អាចត្រូវបានអះអាងថា បាននាំមកនូវផលប្រយោជន៍រួមនៃអភិបាលកិច្ចជាសកល ។